Formation, Dialogue, Cooperation

# អ្នកនាំសារ

# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣១ ខែកក្កដា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៨៨



## សេចក្តីជូនដំណឹង

"ឈាមរបស់មរណសាក្សីគឺគ្រាប់ពូជរបស់ព្រះសហគមន៍" (Apologeticus, Chapter 50:Tertullian)។ បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជា លូតលាស់ដោយសារឈាមមរណសាក្សី។ ខ្ញុំ,លោកបូជាចារ្យ រឿង ធ័ត្រសិរី អ្នករៀបចំសុំណុំរឿង(Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្តល់ពត៌មានបន្ថែមអំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀត ដូចជា រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរ វត្ថុអនុសាវរីយ៍របស់គាត់ខ្លះ ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

អ៊ីម៉ែល ៖ martyrscambodia@gmail.com ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# រូបថតសកម្មភាពរបស់ ព្រះសហគមន៍ទាំង 3 ភូមិភាគ



ដំណើរទស្សនកិច្ចរបស់លោកអភិបាលអូលីវីយេទៅកំពង់សោម។



កម្មវិធីសំណាក់ប្រចាំឆ្នាំរបស់កូនសិស្សអប់រំជំនឿនៅព្រះសហគមន៍កាតូលិកបាត់ដំបង។ រូបថត: ប៊ុនរឿន



ព្រះសហគមន៍កំពង់ចាមធ្វើការប្រកួតបាត់ទាល់ ។រូបថត: ស្រីម៉ាច និងរ៉ាវី



ប្រគណកម្មការរៀនចំកម្មវិធីយុវជនកម្ពុជា-ឡាវ។ រូបថត: សុធីរិទ្ធិ



Kampong Cham's Staff on holiday in Siem Reap

អម៉ាព្យូផែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | |
|---|---|
| ភ្នំពេញ | : **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពត | : **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

## "ខ្ញុំត្រូវការអ្នក"

*ជាកម្មវិធីវិទ្យុសម្រាប់យុវជន*

ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក

Radio Veritas Asia

Crossing Borders, Sharing Christ

វិទ្យុវ៉េរីតាស់អាស៊ី (RVA) ផ្សាយតាមរលកធាតុអាកាសខ្លី (SW)
ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :
ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី
១១៨៥០គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

**វិទ្យុវ៉េរីតាស់អាស៊ី ២៤ម៉ោង តាមប្រព័ន្ធអ៊ីនធឺណែត**

លោកអ្នកអាចស្តាប់កម្មវិធី វិទ្យុវ៉េរីតាស់អាស៊ី ២៤ម៉ោង
តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬ ប្រព័ន្ធ IOS
ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia
រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុងជាភាសាខ្មែរ (RVA Khmer)។

**វិទ្យុវ៉េរីតាស់អាស៊ី (RVA) ផ្សាយតាមវិទ្យុ (FM)**
**ជាភាសាខ្មែររយៈពេល៥០នាទីរាល់ថ្ងៃ :**

ភ្នំពេញ : FM 104 Mhz ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ
កំពង់ធំ : FM 103.5 Mhz ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ
សៀមរាប : FM 107.5 Mhz ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ
កំពង់ចាម : FM 100.5 Mhz ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ
ព្រះសីហនុ : FM 92.5 Mhz ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ
កំពត : FM 93.25 Mhz ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ



**ស្តាប់វិទ្យុវ៉េរីតាស់អាស៊ី (RVA)**
**លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន**
**ទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាន**
**នានាពីព្រះសហគមន៍កាតូលិកកម្ពុជា។**


# ព័ត៌មានកាតូលិកអន្តរជាតិ

## សម្តេចប៉ាប ជួបលោកពូទីនរហូតដល់៥០នាទី

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ និងលោក ប្លាទីមៀ ពូទីន ប្រធានាធិបតីរុស្ស៊ីបាន ជួបគ្នានៅក្នុងជំនួបបិទទ្វារ រហូតដល់ទៅ៥០នាទីនៅក្នុងជំនួបកាលពីសប្តាហ៍មុននេះ។

បណ្តាញព័ត៌មាន អេភី បានរាយការណ៍ថា ទោះបីជាលោក ពូទីនមកជួបសម្តេចប៉ាប យឺតរហូតដល់ទៅ ១ ម៉ោង និង២០នាទី ប៉ុន្តែប្រមុខរដ្ឋទាំងពីរគឺនៅតែបន្តពិភាក្សាគ្នា ។

នៅក្នុងជំនួបនោះ ប្រភពដដែលបានឲ្យដឹងថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានជំរុញឲ្យប្រធានាធិបតីរុស្ស៊ី ឲ្យគិតអំពីសន្តិភាព នៅក្នុងភាគខាងកើតរុស្ស៊ី ដើម្បីនាំមកនូវ សន្តិភាពពិតប្រាកដមួយដល់អ៊ុយក្រែន ប៉ុន្តែសម្តេចប៉ាបក៏មិនបាន ដាក់សំពាធណាមួយលើលោកពូទីនដែរ ។

ក្រៅពីវិបត្តិនៅ អ៊ុយក្រែន ប្រភពដដែលបានឲ្យដឹងថា សម្តេចប៉ាប និងលោក ពូទីន ក៏បានពិភាក្សាគ្នាអំពីបញ្ហាកាតូលិក ដែលជាអ្នកដែលមានជំនឿភាគតិចបំផុតនៅក្នុងប្រទេសរុស្ស៊ី និងបញ្ហានៅមជ្ឈឹមបូព៌ាផងដែរ ។

ពាក់ព័ន្ធនឹងអ៊ុយក្រែននេះ រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន និង បណ្តាប្រទេសឧស្សាហកម្មធំៗទាំង៧ នៅលើពិភពលោកបានគំរាម នឹងជំរុញឲ្យបង្កើនទណ្ឌកម្មបន្ថែមទៀត ដល់ប្រទេសរុស្ស៊ី៕

## ឈាមនៃមរណសាក្សី គឺជាគ្រាប់ពូជនៃការឯកភាព នៅក្នុងព្រះសហគមន៍

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃសុក្រសប្តាហ៍មុន បានទទួលជួបប្រមុខដឹកនាំ នៃសាសនាអូតូដុក នៃប្រទេសរុស្ស៊ី គឺបព្វជិត អ៊ីញ៉ាត្យ៊ី អាប៉ារ៉ាម ទី២ នៅបុរីវ៉ាទីកង់ ។

វិទ្យុវ៉ាទីកង់ បានឲ្យដឹងថា នៅក្នុងជំនួបនោះសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានលើកឡើងអំពីចំណងនៃឯកភាព និងភាតរភាព នៃការបង្រួបបង្រួមព្រះសហគមន៍រ៉ូម ទៅនឹងព្រះសហគមន៍នៃអង់ទីយ៉ូក ដោយរំលឹកឡើងវិញនូវខ្លឹមសារនៃជំនួបរវាងសម្តេចប៉ាប យ៉ូ ហានប៉ូលទី ៦ និងប្រមុខអតូដក ម៉ អ៊ីញ៉ាត្យ៊ី ចាកូប ទី២ ព្រមទាំងសម្តេចប៉ាប សន្តយ៉ូហានប៉ូល ទី២ និងប្រមុខ អូតូដុក អ៊ីញ៉ាត្យ៊ី ហ្សាការ អ៊ីវ៉ាស ទាំងនៅក្នុងទីក្រុង រ៉ូម និងទីក្រុង ដាម៉ាស។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ពួកគេគឺសុទ្ធតែជាមរណសាក្សី នៃគោលគំនិតឯកភាពសាសនាគ្រីស្ត ប៉ុន្តែនៅពេលបច្ចុប្បន្ននេះវិញតើគោលគំនិតនេះ បានរីកចម្រើនដល់ណាហើយ។

នៅក្នុងឱកាសនោះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានស្នើរឲ្យមានការអធិដ្ឋានទៅវិញទៅមកមួយ ទៅដល់ជនរងគ្រោះ នៃអំពើហិង្សាទាំងឡាយ ជាពិសេសគឺជនរងគ្រោះនៅក្នុងសង្គ្រាម ៕



រូបថតៈ ពិសី

# ទស្សនៈពីការចម្លងប្រាសាទអង្គរ៖ នោះជាមោទនៈភាព តែកម្ពុជានឹងខាតបង់

សាធារណៈជនទូទៅនៅកម្ពុជា ខ្លះឯកភាពខ្លះមិនឯកភាព ចំពោះគម្រោងដែលឥណ្ឌា សាងសង់ ប្រាសាទអង្គរវត្តចម្លងមួយនៅឥណ្ឌា ប៉ុន្តែទាំងអស់គ្នាសុទ្ធតែថាមានជំនឿថា នេះគឺជាការខាតបង់មួយរបស់កម្ពុជា ទោះតិចឬច្រើនក្តី។

គម្រោងដែលថា ឥណ្ឌាគ្រោងនឹងកសាង ប្រាសាទអង្គរវត្តចម្លងមួយពីកម្ពុជា ត្រូវបានគេល្បីជាយូរមកហើយ ប៉ុន្តែវាបានកើតមានឡើងយ៉ាងពិតប្រាកដហើយសាធារណជនទូទៅ នៅកម្ពុជាបានដឹងក្រោយពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៥កន្លងទៅថ្មីៗ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្ញើកំណត់ទូតត៍វា ទៅក្រសួងការបរទេសឥណ្ឌា ។

ក្រសួងការបរទេស បានអះអាងថា ក្រសួងបានទទួលដំណឹង ពីគម្រោងសាងសង់នេះតាមរយៈ ស្ថានទូតខ្មែរប្រចាំនៅប្រទេសឥណ្ឌាថា ក្រុមហ៊ុនម៉ាហាវ៉ា ម៉ាន់ឌៀ ត្រាស់ (MAHAVIR MANDIR TRUST) មានគម្រោងសាងសង់ប្រាសាទ ដោយចម្លងតាមប្រាសាទអង្គរវត្តហើយក្រសួង ក៏បានស្នើសុំឲ្យឥណ្ឌាបញ្ឈប់គម្រោងសាងសង់ ប្រាសាទដែលចម្លងតាមរចនាបថប្រាសាទអង្គរវត្តនេះ។

យោងទៅតាមកំណត់ទូតត៍វា ចុះថ្ងៃទី០៦ខែមិថុនារបស់ក្រសួងការបរទេស បានឲ្យដឹងថា រដ្ឋាភិបាលកម្ពុជា បានចាត់ទុកការសាងសង់ប្រាសាទចម្លងតាមប្រាសាទអង្គរវត្ត ដើម្បីផលប្រយោជន៍ពាណិជ្ជកម្មនេះថា គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដល់សម្បត្តិបេតិកភណ្ឌពិភពលោក។ សម្បត្តិបេតិកភណ្ឌពិភពលោក ដែលមានតម្លៃមនុស្សជាតិលេចធ្លោជាសកល។

ប្រាសាទអង្គរវត្ត ជានិមិត្តរូបដែលមាននៅក្នុងទង់ជាតិកម្ពុជា ជាច្រើនសតវត្សមកហើយ។ ក្រសួងការបរទេសកម្ពុជា បានស្នើឲ្យក្រសួងការបរទេសឥណ្ឌា ពិចារណាយ៉ាងម៉ត់ចត់ជាបន្ទាន់នូវគម្រោងសាងសង់ចម្លងតាមប្រាសាទអង្គរវត្តរបស់ខ្មែរ ដើម្បីថែរក្សាទំនាក់ទំនងប្រពៃណីជាប្រវត្តិសាស្ត្ររវាងប្រទេសនិងប្រជាជននៃប្រទេសទាំងពីរ ។

ក្រោយពេលកំណត់ទូត បានផ្ញើចេញ សារព័ត៌មាននានា នៅក្នុងប្រទេស និងក្រៅប្រទេសបានដកស្រង់ ហើយមតិចម្រុះមួយបានផ្សព្វផ្សាយ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋកម្ពុជា សុទ្ធតែយល់ថា នេះគឺជាការខាត់បងមួយរបស់កម្ពុជា ។

លោក ហូ វណ្ឌី អតីតសហប្រធានក្រុមការងារ នៃវិស័យទេសចរណ៍ផ្នែកឯកជន បានអះអាងថា តាមបណ្តាញទំនាក់ទំនងសង្គមរបស់លោក កាលពីពេលថ្មីៗនេះថា នេះគឺជាខាតបង់មួយរបស់កម្ពុជា ។

លោកបានសរសេរ នៅក្នុងបណ្តាញសង្គមរបស់លោកថា "បើសិនពលរដ្ឋ និងរដ្ឋាភិបាលឥណ្ឌា ពិតជាមានការគោរព និងស្រឡាញ់ចំពោះពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជាមែននោះ សូមកុំឲ្យកើតមានការសាងសង់ប្រាសាទស្រដៀងនឹងប្រាសាទអង្គរវត្ត ដែលជាដួងព្រលឹងរបស់ខ្មែរទាំងមូល និង កុំឲ្យមានការភ័ន្តច្រឡំប្រវត្តិសាស្ត្ររាប់រយឆ្នាំ ទៅមុខទៀត" ។

លោក ដួង វិចិត្រ ប្រជាពលរដ្ឋមួយរូបបានអះអាងថា ឥណ្ឌាមិនគួរណាធ្វើដូច្នេះទេ ។ តាមប្រវត្តិសាស្ត្រ ឥណ្ឌាគឺជាគ្រួសារដើមរបស់កម្ពុជា តែបែរជាមកចម្លងឬធ្វើត្រាប់តាមកម្ពុជា ។

លោក វិចិត្រ បានអះអាងថា នេះគឺជាមោទនៈភាពរបស់ខ្មែរ ប៉ុន្តែប្រសិនបើឥណ្ឌាសាងសង់ ប្រាសាទអង្គរវត្តចម្លងបែបនេះមែនវានឹងអាចនាំឲ្យកម្ពុជាខាតបង់សេដ្ឋកិច្ចមួយបាន ។

លោកបញ្ជាក់ថា "ខ្ញុំមិនជាអ្នកចេះដឹងអីទេតែខ្ញុំយល់ថាវាគឺជាមោទនៈភាពរបស់ខ្មែរ ដែលគ្រួសារមកចម្លងពីសិស្ស ប៉ុន្តែបើឥណ្ឌាសាងសង់ ចង់មិនចង់គឺថាផលប៉ះពាល់កំរិតណាមួយនឹងកើតមានចំពោះប្រាសាទអង្គរវត្តកម្ពុជា"។

លោកបានបន្តថា ភ្ញៀវទេសចរមួយចំនួន គឺអាចនឹងមិនមកកម្ពុជា ដោយសារតែគេបានឃើញ ប្រាសាទអង្គរវត្តនៅឥណ្ឌារួចទៅហើយនោះ ។

លោក ឃាម សុភត្រា ជាមន្ត្រីសង្គមស៊ីវិលមួយរូប បានមានប្រសាសន៍ថា រឿងខាតបង់សេដ្ឋកិច្ច រឿងបាត់បង់ភ្ញៀវទេសចរបរទេស គឺជារឿងដែលប្រាសាទអង្គរវត្តយើងជៀសមិនរួចទេ ប៉ុន្តែមតិលោកយល់ថា ការសាងសង់របស់ឥណ្ឌា វាអាចជាការជួយផ្សព្វផ្សាយ ពីប្រាសាទអង្គរវត្តរបស់កម្ពុជាដែរ ។

លោកបានបញ្ជាក់ថា "ខ្ញុំគិតថា វាអាចជួយផ្សព្វផ្សាយពាណិជ្ជកម្មមួយឲ្យប្រាសាទអង្គរវត្តយើងដែរ ដោយសារតែនៅពេលគេឃើញប្រាសាទចម្លង គេច្បាស់ជាចង់ដឹងថា ប្រាសាទដើមនោះវាអស្ចារ្យប៉ុណ្ណា ប៉ុន្តែសំខាន់បើអ្នកមិនសូវមានថវិកា ប្រហែលជាបញ្ចប់ត្រឹមនោះ ដោយសារតែគេអាចយល់ថា ដូចគ្នាក៏ថាបាន"។

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍កាលពីពេលថ្មីៗកន្លងទៅនេះថា វាជាមោទនៈភាពណាស់ ដែលប្រទេសឥណ្ឌា ដែលមាន ប្រជាពលរដ្ឋជាង ១ពាន់លាននាក់មកចម្លងស្នាដៃបុព្វបុរសខ្មែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ លោកក៏បានបង្ហាញអំពីគំនិតមិនគាំទ្រ ឲ្យឥណ្ឌាធ្វើការសាងសង់ ប្រាសាទចម្លងបែបនេះដែរ ។

ប្រាសាទអង្គរវត្តចម្លង ដែលឥណ្ឌាគ្រោងនឹងសាងសង់នោះ គឺមានឈ្មោះថា ប្រាសាទវីរាអាត រ៉ាម៉ាយ៉ាន ម៉ាឌៀ (Viraat Ramayan Mandir)។ វាគឺជាប្រាសាទដែលឥណ្ឌា គ្រោងសាងសង់ មានកំពូលចំនួន១៨ និងកម្ពស់ប្រមាណ១១៥ម៉ែត្រ សាងសង់លើផ្ទៃដីជាង៨០ហិចតា៕

*ដោយអរិយបុត្រ*

# យុវសិស្សវិទ្យាល័យព្រួយបារម្ភនឹងការប្រឡង តែប្ដេជ្ញាថានឹងខំរៀន



*រូបថតៈ លីហៀង*

ការប្រលងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ គ្រោងនឹងធ្វើនៅខែក្រោយ ខណៈដែលយុវសិស្ស វិទ្យាល័យភាគច្រើនកំពុងតែព្រួយបារម្ភ ប៉ុន្តែបានបង្ហាញពីការប្ដេជ្ញាចិត្តនៅក្នុងការត្រៀមយកការប្រឡង ដែលក្រសួងអប់រំ យុវជន និង កីឡា បានអះអាងថានឹងបន្តពង្រឹង ។

ប្អូន ឆាយ សាមីត ជាយុវសិស្សទី១២ នៃ វិទ្យាល័យសម្ដេច ហ៊ុន សែន ភ្នំពេញថ្មី បាននិយាយថា ខ្លួនមានការព្រួយបារម្ភណ៍យ៉ាងខ្លាំង ចំពោះការប្រលងនេះ។ ការព្រួយបារម្ភណ៍នេះ សំដៅទៅលើ ទីមួយ ការរឹតបន្តឹងពីស្ថាប័នក្រសួងអប់រំ និងមានការត្រួតពិនិត្យ ពីអង្គភាពប្រឆាំងអំពើពុករលួយ ប៉ុន្តែប្អូននូវតែជឿជាក់ថា ប្អូននឹងប្រលងជាប់ ដោយយោងទៅតាមការខិតខំប្រឹងប្រែងស្រាវជ្រាវ គឺការធ្វើលំហាត់ដោយខ្លួនឯងនៅផ្ទះ និង រៀនគួរបន្ថែមអាចឲ្យប្អូនស្គាល់ពីគន្លឹះ នៃលំហាត់បានច្រើន។

ជុំវិញការប្រឡងនេះ ប្អូនបានបញ្ជាក់ថា "ខ្ញុំព្រួយបារម្ភខ្លាំង ដោយសារថាឆ្នាំនេះអត់មានអំពើពុករលួយ ឬបន្ទរបន្ទយ ឬក៏បែកវិញ្ញាសារ ឬការសូកប៉ាន់ ស៊ីសំណូកអីនោះទេ "។

ឆាយ សាមីត បានអះអាងថា "មកដល់ពេលនេះគឺខ្ញុំកំពុងតែខំរៀនគួរ អនុវត្តលំហាត់ និង ស្រាវជ្រាវរាល់ថ្ងៃ ដើម្បីឲ្យស្ទាក់ជំនាញ"។

ចំណែកឯប្អូនស្រី ភាព មុន្នីរត្ន សិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ហ៊ុន សែន បុរីមួយរយខ្នង ប្អូនក៏មានបង្ហាញអំពីការព្រួយបារម្មណ៍ យ៉ាងខ្លាំងចំពោះការប្រឡងនៅពេលខាងមុខ របស់ប្អូនផងដែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ប្អូនបានអះអាង អំពីការត្រៀមទុកជាមុនទាំងចំណេះ និងស្មារតី ។

មុន្នីរត្ន បានចែករំលែកការព្រួយបារម្ភរបស់ប្អូនថា បើតាមប្អូនធ្លាប់ឮតាមព័ត៌មានទូរស្សន៍ វិទ្យុ ថាក្រសួងអប់រំ យុវជន និង កីឡា នឹងធ្វើការរិតបន្តឹងការប្រឡងរបស់ប្អូនជាងឆ្នាំមុនៗ ហើយចំពោះវិញ្ញាសារក៏តឹងដែរ ជាពិសេសចំពោះមុខវិជ្ជា វិទ្យាសាស្ត្រ ដូចជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវៈវិទ្យា គឺជាមុខវិជ្ជាសំខាន់ ដោយឡែកមុខវិជ្ជាប្អូនទៀត គឺមុខវិជ្ជាពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា ផែនដីវិទ្យាក៏ព្រួយបារម្ភដែរ ដោយសារមិនដឹងថាចេញអ្វី។

ប្អូនស្រីបាន បន្តទៀតថា ចំពោះភាគរយ នៃការប្រលងជាប់មានច្រើនដោយស្ថិតនៅលើ ការខិតខំប្រឹងប្រែងតាមរយៈការរៀនគួរជារៀងរាល់ថ្ងៃ ។

មុន្នីរត្ន បានបន្តទៀតថា ក្រៅពីខំធ្វើការស្វ័យសិក្សា ដោយខ្លួនឯងជារៀងរាល់ថ្ងៃហើយនោះ ប្អូនស្រីក៏បានត្រៀមហ្វឹកហាត់ផ្លូវចិត្ត និងអារម្មណ៍ផងដែរ។

ប្អូនស្រីបានបញ្ជាក់ថា " ផ្លូវអារម្មណ៍ក៏សំខាន់ដែរ ពីព្រោះជួនកាលយើងចេះ តែដល់ពេល យើងឃើញអនុរក្សច្រើនពេក យើងភ័យយើងភ្លេចរូបមន្តអីធ្វើលំហាត់មិនចេញ។

ប្អូនស្រី គង់ រតនាទេពី ជាយុវសិស្សនៅវិទ្យាល័យបុរី ១០០ខ្នង ក៏បានចែករំលែក និងអះអាងអំពីការត្រៀមខ្លួនរបស់ប្អូនស្រីចំពោះការប្រឡងនៅពេលខាងមុខនេះផងដែរ ។

ប្អូនស្រីបានបញ្ជាក់ថា "ខ្ញុំព្រួយបារម្ភខ្លាំង ពីព្រោះឆ្នាំនេះអ្នកណាៗក៏និយាយដែរថា ឆ្នាំនេះការប្រឡងមានការរិតបន្តឹងខ្លាំង ទាំងស្ថានភាពប្រឡង នៅក្នុងថ្នាក់ ហើយវិញ្ញាសារ គឺក៏ពិបាកជាងមុខផងដែរ"។

ប្អូនស្រីបានបញ្ជាក់ថា បើនិយាយអំពីសង្ឃឹម នរណាក៏សង្ឃឹមដែរ ហើយខ្ញុំវិញ គឺជឿជាក់លើខ្លួនឯង ប៉ុន្តែសំខាន់នៅពេលនោះមិនដឹងថា វាយ៉ាងម៉េចពោលគឺអាស្រ័យលើសមត្ថភាព។

ទេពី បានអះអាងថា ក្នុងចំណោមមុខវិជ្ជាទាំងអស់ មុខវិជ្ជាដែលទេពីព្រួយបារម្ភជាងគេនោះ គឺមុខវិជ្ជាមេរៀនដែលមានប្រវត្តិវិទ្យា ភូមិវិទ្យា ។ល។

ជុំវិញបញ្ហានៃការរៀបចំ ការប្រឡងនេះ លោក អ៊ុំ សំអាត ជាអាណាព្យាបាលមួយរូប បានមានប្រសាសន៍ថា ឆ្នាំនេះលោកមានកូនប្រុសមួយរូប និងក្មួយស្រី ៣ រូប ត្រូវប្រឡងសញ្ញាបត្រទុតិយភូមិនៅក្នុងពេលខាងមុខនេះដែរ ។

លោកបានអះអាងថា លោកព្រួយបារម្ភអំពីសមត្ថភាពកូន និងក្មួយរបស់លោកដែរ ដោយសារតែគេនិយាយថា ការប្រឡងឆ្នាំនេះតឹង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គឺលោកគាំទ្រឲ្យមានការរៀបចំតឹងរឹងបែបនេះ ។

លោកបញ្ជាក់ថា "ខ្ញុំជឿជាក់ថា ជាអាណាព្យាបាលម្នាក់ នរណាក៏ព្រួយបារម្ភពីកូនៗដែរ ដោយសារតែនេះគឺជាទ្វារអនាគតរបស់គេ ប៉ុន្តែបើវាធូររលុងដូចកាលពីមុនឆ្នាំ ២០១៤ ក៏វាគ្មានន័យអីដែរ "។

លោកបានបន្តទៀតថា ការប្រឡងវាមានន័យស្អី បើពេលប្រឡងមិនទៅប្រឡង បែជាទៅចម្លង ហើយនរណាៗក៏ជាប់សូម្បីតែក្មេងអត់ដែលចូលសាលាក៏ជាប់ដែរនោះ ។

លោក រិន សិទ្ធចន្ថា ដែលជាអាណាព្យាបាលមួយរូប បានបញ្ចេញមតិថា លោកគាំទ្រឲ្យមានការរិតបន្តឹង ដូចជាវិធានការ កាលពីឆ្នាំ ២០១៤ ដែលក្រសួងបានធ្វើ ទោះបីជាលោកមានកូនដែលចូលរួមប្រឡងសញ្ញាបត្រនេះ នៅពេលខាងមុខនេះក៏ដោយចុះ ។

លោកបានបញ្ជាក់ថា "ជាឪពុកមួយរូប ចង់ឲ្យកូនជាប់ដូចគ្នា តែខ្ញុំកាត់ចិត្ត ហើយ ជាប់ឬមិនជាប់ឲ្យវាដឹងនៅពេលនោះហ្មង។ វាជាតម្លៃរបស់វា កុំដូចឆ្នាំមុនៗ ចង់អ្នកមិនចេះម៉េចក៏ចេះតែជាប់ដែរនោះ"។

តាមការគ្រោងទុក សម័យប្រឡងសញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ នៅក្នុងឆ្នាំនេះគ្រោងនឹងរៀបចំឡើងនៅក្នុងរង្វង់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ខាងមុខ ហើយក្រសួងអប់រំ យុវជន និងកីឡា ក៏បានប្រកាសជូនដំណឹងអំពីការរៀបចំមណ្ឌលប្រឡងរួចរាល់ហើយដែរ៕

*ដោយអរិយបុត្រ*





រូបថត: ????

# លោកសិលា សុខណា ជាបូជាចារ្យ ជាតិកម្ពុជា ទី៨

ក្បួនដង្ហែរយ៉ាងឱឡារឹក ជាមួយនិង ការស្មូទំនុកតម្កើង អបដំណើរ លោក ឧបដ្ឋាក សិលា សុខណា ចូលក្នុង វេទិការ ដើម្បីទទួលអគ្គសញ្ញាតែងតាំង ជាបូជាចារ្យ ដែលជាអំណរសប្បាយ របស់ព្រះសហគមន៍កាតូលិកកម្ពុជា ជា ពិសេសភូមិភាគភ្នំពេញ។ ពិធីនេះបាន ប្រព្រឹត្តទៅ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច ភ្នំពេញ នាព្រឹកថ្ងៃទី ២៧ មិថុនា ២០១៥នេះ ដែលមានលោក អភិបាលអូលីវីយេ ឆ្មឹតអ៊ីស្លែរ ជាអធិបតី ក្រោមអធិបតីភាព លោកអភិបាល អូលីវីយេ ឆ្មឹតអ៊ីស្លែរ ដោយមានការចូល រួមពីសំណាក់លោកអភិបាល និងបូជាចារ្យជាច្រើនរូប ដែលមានវត្តមានក្នុង ប្រទេសកម្ពុជា និង គ្រីស្តបរិស័ទជាង ២០០០នាក់។

បន្ទាប់ពីក្បួនសង្ហែរ បានមកដល់ វេទិការរួចរាល់ លោកបូជាចារ្យ អ៊ុន ស៊ុន បានកោះហៅបេក្ខជន សិលា សុខ ណា ឲ្យបង្ហាញខ្លួនមុខគ្រីស្តបរិស័ទទាំងអស់។ បន្ទាប់មកលោកបូជាចារ្យ រ៉ូប៊ឺត ពីសេ ដែលជានាយកទេវវិទ្យាល័យ បានស្នើរ សុំលោកអភិបាលអូលីវីយេ ដោយអះ អាងថា លោកសិលា សុខណា ពិតជា មានសម្ថភាព ក្នុងការទទួលអគ្គសញ្ញា តែងតាំង ធ្វើជាបូជាចារ្យពិតប្រាកដ មែន។

ជាមួយគ្នានេះដែរ លោក ម៉ារីយ៉ូ ហ្គេហ្ស៊ី ជាតំណាងពេញសិទ្ធរបស់លោក អភិបាលអូលីវីយេ បានឡើងប្រកាស ជាសាធារណៈ អំពីគុណសម្បត្តិរបស់ បេក្ខភាពសុខណា ចាប់តាំងពីថ្ងៃដែល លោកបានស្គាល់ គឺបេក្ខជនរូបនេះតែង យកចិត្តទុកដាក់ចំពោះមិត្តភាពជាមួយ ព្រះយេស៊ូដោយអធិដ្ឋានទទួលស្គាល់ពី វត្តមានរបស់ព្រះយេស៊ូនៅក្នុងជីវិតយក ចិត្តទុកដាក់ជាមួយអ្នកក្រីក្រ ដោយ យល់ថា អ្នកទាំងនោះជាតំណាងព្រះ យេស៊ូដែលកំពុងលំបាកពិតមែន។លោក សុខណា បានយកចិត្តទុកដាក់អំពីពិធី បុណ្យ (អភិបូជា) ដោយស្ម័គ្រចិត្តជួយ ណែនាំក្រុមបម្រើអាសនៈ លោកតែងតែ ចាប់អារម្មណ៍ ចំពោះអ្នកដែលស្វែងរក ការត្រាស់ហៅឲ្យធ្វើជាបព្វជិត បព្វជិតា និងមានបំណងធ្វើសាសនទូត ដើម្បី ប្រកាសដំណឹងល្អ ដល់បងប្អូនឯ ទៀតៗ។

ដោយយោងតាមអំណះអំណាងនិង ការស្នើរសុំខាងលើ លោកអភិបាល បាន ប្រកាសជ្រើសរើស លោក សិលា សុខណា ឲ្យទទួលអគ្គសញ្ញាតែងតាំង ជាបូជាចារ្យ ដោយមានការគាំទ្រពីព្រះ យេស៊ូផងដែរ។

ក្នុងធម្មទេសនា លោកអភិបាលបាន មានប្រសាសន៍ថា នេះជាគំរោងការ របស់ព្រះជាម្ចាស់ និងផលផ្លែដែលកើត ចេញពីការអធិដ្ឋាន និងគំរូរបស់បង ប្អូន។ ថ្ងៃនេះលោកសុខណា លែងជា ឧបដ្ឋាកទៀតហើយ ទេជាមិត្តសម្លាញ់។ លោកបញ្ជាក់ថា នេះមិនមែនជាពាក្យ ដែលចេញពីបបូរមាត់របស់លោកទេ តែ ជាព្រះបន្ទូល របស់ព្រះយេស៊ូផ្ទាល់ ។ លោកបន្តថា ដោយសារអំណាចនៃព្រះ វិញ្ញាណដ៏វិសុទ្ធ ដោយសារការទ្រាបដៃ លោកសុខណា នឹងទៅជាបូជាចារ្យ ទៅ ជាមិត្តសម្លាញ់ ដែលព្រះយេស៊ូបាន ជ្រើសរើស និងខ្ញីខ្លួនសុខណា ឲ្យបូជា ជីវិតរួមជាមួយព្រះយេស៊ូ ដើម្បីយើង ទាំងអស់គ្នាទទួលជីវិតថ្មី ទទួលសុភមង្គលពិតប្រាកដ គឺមានន័យថា ទទួល ការសងគ្រោះ ដែលជាអាថ៌កំបាំងរបស់ បូជាចារ្យទាំងអស់ ដែលខិតខំរស់នៅ ក្នុងជីវិតរបស់បូជាចារ្យ។

លោកអភិបាល ក៏បានណែនាំគ្រីស្ត បរិស័ទទាំងអស់ ជាពិសេស លោក បូជាចារ្យថ្មី ដើម្បីចូលយ៉ាងជ្រៅជាជីវិត ជាបូជាចារ្យដោយគោលដៅ៤សំខាន់ៗ គឺមានជំនឿ គឺចាប់ពីពេលនេះតទៅ លោកសុខណា លែងមានជីវិតជាឯកជន ទៀតហើយ គឺលោកបូជាជីវិតជាសាធារណៈសម្រាប់ព្រះយេស៊ូ និងក្នុងព្រះ យេស៊ូ គឺបម្រើព្រះសហគមន៍ដោយចិត្ត ស្មោះ អប់រំបងប្អូនឯទៀតៗ ឲ្យទៅជា ឆ្លុងតែមួយជាមួយព្រះគ្រីស្ត និងជា គង្វាលដ៏សប្បុរស ដើម្បីឲ្យយើងទៅជា សេចក្តីស្រឡាញ់ ដ៏ពេញលក្ខណៈ សម្រាប់មនុស្សទាំងអស់។

លោកបន្តថា៖ ត្រូវដាក់ខ្លួន ដោយ យកព្រះនាងម៉ារី សន្តយ៉ូសែប និង លោកយូហានបាទីស្ត អ្នកម្តាយតេរេសា ជាគំរូនៃជំនឿ ដែលដាក់ខ្លួនគ្រប់ពេល វេលា ដើម្បីបង្ហាញពីវត្តមានព្រះគ្រីស្ត និងឧបការគុណរបស់ព្រះជាម្ចាស់ ដល់ បងប្អូនឯទៀតៗ។

ព្រមជាមួយគ្នានេះ ត្រូវមានចិត្តមេត្តា ករុណា ប្រណីសណ្តោស ដែលជា របៀបព្រះយេស៊ូលើកលែងទោស និង មើលអ្នកដែលពិបាក ដោយចិត្តស្រឡាញ់ របស់ព្រះអង្គ។ លោកបូជាចារ្យ ត្រូវ បូជាសម្រាប់មនុស្សទាំងអស់ គឺមិនមែន សម្រាប់តែក្រុមមួយដែលយើងស្រឡាញ់ យើងស្គាល់តែប៉ុណ្ណោះទេ។

លោកអភិបាល ក៏មានផ្តាំផ្ញើរដល់ គ្រីស្តបរិស័ទទាំងអស់ ជាពិសេសដល់ យុវជនយុវនារី ឲ្យភ្ញាក់ស្មារតីឆ្លើយតាម នឹងការត្រាស់ហៅ ដើម្បីឲ្យមានបព្វជិត បព្វជិតាយ៉ាងច្រើនក្នុងប្រទេសកម្ពុជា។ ជាងនេះគ្រីស្តបរិស័ទក៏ត្រូវឲ្យចេះគោរព ពេលវេលាលោកបូជាចារ្យផងដែរ។

ពិធីតែងតាំង ធ្វើឡើងដោយលោក អភិបាលទ្រាបដៃ រួមជាមួយបូជាចារ្យ ទាំងអស់ម្តងម្នាក់ៗ ដើម្បីបញ្ជាក់ថា អស់លាករួបរួមជាមួយអភិហាលរបស់ ខ្លួន ដើម្បីអង្វរព្រះវិញ្ញាណដ៏វិសុទ្ធដើម្បី តែងតាំងលោកសុខណាជាបូជាចារ្យ។

លោកបូជាចារ្យថ្មី សុខណា ទទួល ឯកសណ្ឋានជាបូជាចារ្យ និងត្រូវបាន លោកអភិបាល លាបប្រេងគ្រីស្មា លើ បាតដៃ ដើម្បីឲ្យបូជាចារ្យថ្មីនេះ បាន វិសុទ្ធ ហើយណែនាំប្រជារាស្ត្ររបស់ព្រះ អង្គឲ្យបានវិសុទ្ធ និងដើម្បីថ្វាយសក្ការៈ បូជារបស់ព្រះអង្គ។

លោក សិលា សុខ ណា ដែលបាន ថ្លែងអំណរគុណដល់អស់លោក និងបង ប្អូនដែលតែងតែអធិដ្ឋាន លើកទឹកចិត្ត រហូតដល់មានថ្ងៃនេះ។ លោកបន្តផ្តាំផ្ញើរ ដល់យុវជណយុវនារី ដែលមានបំណង ស្វែងយល់ពីការត្រាស់ហៅ កុំឲ្យភ័យខ្លាច ក្នុងការបើកបេះដូងទទួលស្វាគមន៍ព្រះ យេស៊ូយាងចូលមក ក្នុងដួងចិត្តរបស់ ខ្លួន។លោកបន្តថាសូមយុវជនទាំងអស់

# បទបង្ហាញសំខាន់ណាស់សម្រាប់យុវជននិងការប្រកួតប្រជែង

*លេខនេះអ្នកនាំសារ សូមណែនាំមិត្តអ្នកអាន ឲ្យជួបជាមួយនឹងយុវជនមួយរូប ដែលកំពុងតែដឹកនាំយុវជនមួយក្រុម នៅក្នុងការរៀបចំគម្រោងនៃការប្រកួតប្រជែងធ្វើបទបង្ហាញមួយ ដើម្បីពន្យល់មិត្តអ្នកអានឲ្យយល់អំពីស្ថានភាពពិត នៃការធ្វើបទបង្ហាញ និងបញ្ហាជុំវិញប្រធានបទនេះ ។ យុវជន រូបនេះគឺលោក ជួប មិថុនា ជាសាស្ត្រាចារ្យភាសាអង់គ្លេស នៅវិទ្យាស្ថានភាសាបរទេស និង ជាអ្នកដឹកនាំគម្រោងនេះផ្ទាល់។*

**អ្នកនាំសារ ៖** ជាតំបូងតើគម្រោងដែលលោករៀបចំធ្វើនោះមានឈ្មោះអ្វីដែរ ?

**លោក ជួប មិថុនា ៖** គម្រោងនេះ គឺគម្រោង Our Own Projects & Soiree Event Management។ វាគឺជាគម្រោងទីមួយដែលយើងគ្រោងនឹងរៀបចំ នៅវេទិកាប្រកួតប្រជែង ធ្វើបទបង្ហាញដោយនិស្សិត ដែលកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញពីឆ្នាំទី ១-៤ នាថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៥ខាងមុខនេះ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ។

**អ្នកនាំសារ៖** តើមូលហេតុអ្វី បានជាលោកមានគម្រោងរៀបចំជាកម្មវិធីនេះឡើង ?

**លោក ជួប មិថុនា ៖** គម្រោងនេះគឺចេញមកពីបទពិសោធន៍ដែលយើងធ្វើ កាលពីខ្ញុំនៅជានិស្សិត ។ យើងដឹងថា កាលនៅជានិស្សិត គឺយើងមានការលំបាកនៅក្នុងការនិយាយជាសាធារណៈ ដូច្នេះយើងក៏បានរៀបចំ ជាកម្មវិធីនេះឡើងដើម្បីជំរុញសមត្ថភាពនិយាយ និងការធ្វើបទបង្ហាញដល់និស្សិត ដើម្បីលើកកំពស់ជំនាញនេះ ត្រៀមទុកឲ្យហើយនៅពេលដែលយើងចូលអាស៊ាន។

**អ្នកនាំសារ ៖** តើលោកយល់យ៉ាងម៉េចអំពីសមត្ថភាព នៅក្នុងការធ្វើបទបង្ហាញរបស់យុវនិស្សិតកម្ពុជាយើងសព្វថ្ងៃនេះ បើធៀបនឹងយុវនិស្សិតនៅអាស៊ានផ្សេងៗទៀត។

**លោក ជួប មិថុនា ៖** ខ្ញុំយល់ថា សមត្ថភាពនៅក្នុង ការនិយាយជាសាធារណៈ ជាពិសេស គឺការធ្វើបទបង្ហាញ យើងប្រហែលជានៅមានកំរិត។ យើងកំពុងតែស្ថិតនៅក្នុងស្តង់ដាមួយ នៅក្រោមគេបន្តិច ដូច្នេះប្រសិនបើយើង មានការជួយជំរុញគ្នា ចែករំលែកបទពិសោធន៍គ្នា ដូចដែលយើងមានគម្រោងនឹងធ្វើ គឺវាជាចំណែកមួយដែលជួយលើកកំពស់សមត្ថភាពនេះ ។

**អ្នកនាំសារ ៖** ប្រសិនបើនៅពេលបច្ចុប្បន្ននិស្សិតយើង មិនយកចិត្តទុកដាក់អំពីបញ្ហានិយាយ និងធ្វើបទបង្ហាញនេះ តើលោកយល់យ៉ាងម៉េចដែរ ?

**លោក ជួប មិថុនា៖** ខ្ញុំគិតថា វាគឺជាចំណុចខ្វះខាតមួយ នៅក្នុងការប្រកួតប្រជែង ឧទាហរណ៍នៅក្នុងវិស័យការងារ មុននឹងគេជ្រើសរើសយើងយកធ្វើបុគ្គលិក គឺយើងត្រូវឆ្លងកាត់ការសំភាសន៍ ឬការប្រកួតប្រជែងផ្សេងៗដូច្នេះ ប្រសិនបើយើងខ្វះសមត្ថភាព នៅក្នុងការនិយាយការបង្ហាញពីខ្លួនឯង ទេពកោសល្យដែលខ្លួនឯងមាន យើងនឹងប្រឈមមុខនឹងការបាត់បង់ឱកាស ទោះបីជាការងារនោះយើងគិតថា យើងអាចធ្វើបានដូចគ្នា ហើយល្អជាងគេផងក៏ដោយ ។

**អ្នកនាំសារ ៖** បទពិសោធន៍ផ្ទាល់ខ្លួនវិញ តើកន្លងមក លោកធ្លាប់ជួបបញ្ហាការលំបាកបែបនេះដែរឬទេ ?

**លោក ជួប មិថុនា ៖** ជាការពិតចំពោះខ្លួនខ្ញុំផ្ទាល់គឺធ្លាប់ជួបនូវការលំបាកច្រើន ។ ដោយសារតែតាំងពីតូចមក យើងមិនសូវមានឱកាសនៅក្នុងការនិយាយ បែបនេះទេ ប៉ុន្តែដល់ពេលចូលមហាវិទ្យាល័យ គឺគ្រប់មុខវិជ្ជាទាំងអស់ គឺមានផ្នែកនេះដូច្នេះវាថ្មីហើយមានការលំបាកច្រើន ដោយទីមួយ គឺយើងមានការភ័យខ្លាចពេលនិយាយនៅមុខមនុស្ស និងសាស្ត្រាចារ្យ។ នៅក្នុងរយៈពេលបួនឆ្នាំនេះខ្ញុំត្រូវពេលហ្វឹកហាត់ជាច្រើន ដើម្បីកែលំអរខ្លួនឯងអភិវឌ្ឍន៍ខ្លួនឯង ។

**អ្នកនាំសារ ៖** អាចនិយាយប្រាប់ខ្ញុំបន្តិចបានទេ ថានៅពេលធ្វើបទបង្ហាញដំបូងមានអារម្មណ៍បែបម៉េច ហើយឥឡូវនេះយ៉ាងម៉េច ?

**លោក ជួប មិថុនា៖** ពេលដំបូងគឺភ័យខ្លាំងអត់ដឹងថា គួរចាប់ផ្តើមពីណាទៅណា អត់ហ៊ានបញ្ចេញកាយវិការអ្វីទេ បានត្រៀមនិយាយ គឺភ្លេចអស់ ឥឡូវនេះគឺខុសគ្នា ដោយសារតែខ្ញុំមានភាពក្លាហានច្រើន មិនថាតែនៅក្នុងថ្នាក់ទេ សូម្បីតែនៅក្រៅថ្នាក់ ឬមុខមនុស្សរាប់រយនាក់ ក៏មិនភ័យដូចមុនដែរ ។

**អ្នកនាំសារ៖** ដើម្បីចេះរបៀបធ្វើបទបង្ហាញនេះ តើយើងគួររៀនដោយវិធីណាទៅ?

**លោក ជួប មិថុនា ៖** គឺយើងអាចរៀនពីគ្រូរបស់យើង ព្យាយាមចូលរួមកម្មវិធីផ្សេងៗឲ្យបានញឹកញាប់ រៀនអនុវត្តហើយហានបញ្ចេញយោបល់ ពោលគឺត្រូវរកឱកាសអនុវត្តផ្ទាល់ ដូចករណីខ្ញុំគឺ ខ្ញុំបានចូលរួម Debate Club (ក្លឹបនិយាយពិភាក្សា)។

**អ្នកនាំសារ ៖** នៅក្នុងកាលៈទេសៈឥឡូវបើយុវជន-យុវនារី មិនចេះរបៀបធ្វើបទបង្ហាញបែបនេះ តើជាការលំបាកឬយ៉ាងណា?

**លោក ជួប មិថុនា ៖** វាជារឿងដែលពិបាកសម្រាប់ពួកគាត់ ប្រសិនបើពួកគេមិនចេញជំនាញ ឬមិនមានសមត្ថភាពនេះទេនោះ ដោយសារគាត់ពិបាកនៅក្នុងការទំនាក់ទំនងនៅខាងក្រៅ។

**អ្នកនាំសារ ៖** តើលោកយល់ថា ប្រព័ន្ធអប់រំយើង ឲ្យតម្លៃទៅលើការធ្វើបទបង្ហាញ និងជំនាញនៅក្នុងការនិយាយនេះទេ ?

**លោក ជួប មិថុនា ៖** ខ្ញុំយល់ឃើញថាខ្លះដែរ ប៉ុន្តែតាមការកត់សំគាល់របស់ខ្ញុំ និងបទពិសោធន៍ខ្លួនខ្ញុំផ្ទាល់ កាលនៅតូច គឺមិនសូវមានទេ តែដល់មហាវិទ្យាល័យបានមានច្រើន។

**អ្នកនាំសារ ៖** ដើម្បីឲ្យជំនាញនៅក្នុងការធ្វើបទបង្ហាញ និងនិយាយទៅកាន់សាធារណៈនេះកាន់តែល្អ ថាតើយុវជនយើងម្នាក់ៗគួរតែចាប់ផ្តើមរៀននិយាយរៀនអនុវត្តតាំងពីពេលណាមក?

**លោក ជួប មិថុនា ៖** ខ្ញុំផ្ទាល់គិតថា ការចាប់ផ្តើមអនុវត្តការធ្វើបទបង្ហាញ និងការនិយាយនេះ គួរតែចាប់ផ្តើមតាំងពីក្មេងមក ពោលគឺកាន់តែលឿន គឺកាន់តែល្អ ពោលគឺត្រូវតែបង្កលក្ខណៈឲ្យពួកគាត់ហ៊ាននិយាយ ហ៊ានទំនាក់ទំនងជាមួយនឹងមិត្តភ័ក្រតាំងពីតូចមក ។

**អ្នកនាំសារ៖** ចំពោះគ្រួសារវិញ តើលោកយល់ថា បរិបទសង្គមកម្ពុជាយើងអាណាព្យាបាល ឬឪពុកម្តាយបង្កលក្ខណៈនៅក្នុងគោលគំនិតនេះដែរឬទេ ?

**លោក ជួប មិថុនា ៖** តាមខ្ញុំយល់ថា នៅតាមគ្រួសារ ក្មេងៗហាក់ដូចជាមិនសូវជាទទួលការបើកទូលាយ ឲ្យបញ្ចេញមតិប៉ុន្មានឡើយ។ តាមដែលខ្ញុំឆ្លងកាត់មកគឺថា ក្មេងៗគឺត្រូវតែស្តាប់ចាស់។ វាម៉្យាងដោយសារតែនេះ គឺជាវប្បធម៌របស់យើង ប៉ុន្តែប្រសិនបើជាផ្តល់ឱកាសឲ្យពួកគាត់បន្តិច ក៏គួរតែជាចំណុចល្អដែរ ៕

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រាទី២៣៖**

ហាមឈប់ ឬចតយានជំនិះនៅទីកន្លែងដូចខាងក្រោម៖

- នៅលើថ្រូងផ្លូវ ចិញ្ចើមផ្លូវដែលទុកបម្រុងឲ្យថ្មើរជើង និងក្នុងចន្លោះយ៉ាងតិច ៥ (ប្រាំ)ម៉ែត្រពីមុខគំនូសឆ្នូតកាត់ទទឹងថ្រូងផ្លូវ សម្រាប់ថ្មើរជើង ឬនៅលើគំនូសនេះនៅលើផ្លូវ សម្រាប់ថ្មើរជើង
- លើកន្លែងបម្រុងទុក សម្រាប់ការឈប់ ឬចតនៃយានប្រភេទខ្លះ
- នៅចន្លោះគែមថ្រូងផ្លូវ និង ខ្សែគំនូសបង្ហូត ប្រសិនបើនៅចន្លោះខ្សែគំនូសបង្ហូត និងយានចតនេះតិចជាង ៣(បី) ម៉ែត្រ ដែលមិនអាចឲ្យយានមួយផ្សេងទៀតបរបាន ដោយឥតឆ្លងកាត់ ឬជាន់លើខ្សែរគំនូសបង្ហូត
- នៅជិតបង្គោលភ្លើង សញ្ញាចរាចរណ៍ ឬផ្លាកសញ្ញាចរាចរណ៍ដែលធ្វើឲ្យបាំងភ្នែកអ្នកប្រើប្រាស់ផ្លូវ មិនអាច មើលឃើញសញ្ញាចរាចរណ៍ទាំងនេះបាន
- នៅគ្រប់ទីកន្លែង ដែលធ្វើឲ្យរាំងស្ទះដល់ច្រកចេញចូលការចត ឬការឈប់នៃយានដទៃទៀត
- នៅលើស្ពាន លើផ្លូវក្រោមស្ពាន លើផ្លូវរូង លើផ្លូវប្រសព្វ លើផ្លូវកាត់ផ្លូវរថភ្លើង លើផ្លូវក្នុងរង្វង់មូល ផ្លូវកោងខ្លាំង ឬលើផ្លូវចោតខ្លាំង ដែលមិនអាចមើល យានផ្សេងទៀតពីចម្ងាយបាន
- នៅចន្លោះតិចជាង ២០(ម្ភៃ) ម៉ែត្រពីផ្លូវថតភ្លើងឆ្លងកាត់
- នៅចន្លោះ តិចជាង ១០(ដប់) ម៉ែត្រពីមុខ និងពីក្រោយទីតាំងបូមទឹករបស់យានពន្លត់អគ្គិភ័យ និង នៅមុខស្ថានីយពន្លត់អគ្គិភ័យ។




បាតុករប្រឆាំងចំពោះពង្រាងច្បាប់ថ្មីស្ដីពីអង្គការ សមាគម និងសហជីព ។ រូបថត: ឡុង សម្ផស្ស

# កម្មករនិងកម្មការនីសាមញ្ញមិនយល់ ហើយក៏មិនខ្វល់ពីពង្រាងច្បាប់ ស្ដីអង្គការ សមាគម និងសហជីព

តាមយោបល់របស់កម្មករ និងកម្មការនីនៅម្ដុំទួលសង្កែ ដែលបាននិយាយក្រោយពេលបញ្ចប់ការងារកាលពីសៀលថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១៥ថា ពួកគេហាក់មិនយល់ និងមិនខ្វល់អំពីពង្រាងច្បាប់ ដែលកំពុងតែមានភាពចម្រូងចម្រាស់ រវាងក្រុមអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា ដែលជាអ្នករៀបចំនៃពង្រាងច្បាប់នេះ ។

លោក រិន ភក្ដី ជាកម្មករជ្រលក់ពណ៌មួយរូប បាននិយាយថា លោកមិនដែលបានចាប់អារម្មណ៍នឹងព័ត៌មានអំពីសេចក្ដីព្រាងច្បាប់ ស្ដីអំពីអង្គការ សមាគម និងសហជីពនោះទេ ។

លោកបានបញ្ជាក់ថា "ខ្ញុំមិនដែលបានអានព័ត៌មាន ស្ដាប់វិទ្យុ មើលទូរទស្សន៍ អ្វីអំពីពង្រាងច្បាប់ស្អីនោះទេ"។

លោកបានបន្តទៀតថា នៅរាល់ថ្ងៃវាធ្វើការហត់ពេក ចេញមកពីធ្វើការឲ្យតែដល់ផ្ទះនឹងអាលដាំស្ល ឬទិញម្ហូបហូបបាយ និងដេកយកកម្លាំងតែប៉ុណ្ណោះ ។

កញ្ញា ចក់ ចិន្តា ជាកម្មការនីមួយរូប ដែលកំពុងតែ ស្ថិតនៅក្នុងហ្វូងមនុស្សដើរទិញម្ហូប នៅពេលចេញពីរោងចក្រ បានអះអាងថាកញ្ញាក៏មិនដែលបានតាមដានព័ត៌មានអ្វីដែររាល់ថ្ងៃនេះ ដូច្នេះទាក់ទងនឹងពង្រាងច្បាប់ ដែលកំពុងតែចម្រូងចម្រាស់នេះ កញ្ញាក៏មិនហ៊ានបញ្ចេញយោបល់អ្វីនោះទេ ។

កញ្ញាបានបញ្ជាក់ថា "មិនសូវបានតាមដានព័ត៌មានផងខ្ញុំអត់ហ៊ាននិយាយទេខ្លាចខុស"។

កញ្ញា បានបន្តទៀតថា កន្លងមកព័ត៌មានដែលកញ្ញាបានទទួលអី គឺខាងសហជីព គេជាអ្នកប្រាប់ ឬដឹងតែពីមាត់មួយទៅមាត់មួយតាមៗគ្នា ។

នៅពេលដែលសួរថា នៅពេលទៅដល់ផ្ទះធ្វើអ្វីនៅពេលសម្រាក ឬពេលទំនេរ កញ្ញាបានឲ្យដឹងថា គឺមើលទូរទស្សន៍កម្មវិធីរឿងភាគ ឬក៏មើលតន្ត្រីកំសាន្ត។

លោក សេក យុត្តារិទ្ធ ជាកម្មកររោងចក្រខោខូវប៊ូយមួយរូប បានឲ្យដឹងថា លោកឧស្សាហ៍ស្ដាប់ព័ត៌មាន ហើយក៏បានឮសេចក្ដីរាយការណ៍ព័ត៌មាន អំពីពង្រាងច្បាប់នេះដែរ ប៉ុន្តែហាក់ពុំចាប់អារម្មណ៍ ដូច្នេះហើយបានជាមិនចង់មានយោបល់អ្វីច្រើន ។

លោកបានបញ្ជាក់ថា "តាមខ្ញុំគិតគឺថា ច្បាប់នេះមើលទៅទំនងជាមិនពាក់ព័ន្ធនឹងរឿងប្រាក់ខែ រឿងជីវភាពកម្មករទេ ចឹងហើយបានជាមិនសូវចាប់អារម្មណ៍"។

កញ្ញា បាន រចនា ហៅស្រីអែម បានឲ្យដឹងថា រាល់ថ្ងៃកញ្ញាចង់មើល ចង់ស្ដាប់ព័ត៌មាននឹងគេដែរ តែមិត្តភ័ក្ដិមិនសូវចាប់អារម្មណ៍។

កញ្ញាបានឲ្យដឹងថា "ខ្ញុំចង់ដឹងព័ត៌មានពីស្រុកទេសយើងដែរ ប៉ុន្តែឲ្យតែបើកទូរទស្សន៍ មិត្តភ័ក្ដិចុចមើលតែរឿងនិងចម្រៀង"។

ម្ចាស់ផ្ទះជួលមួយរូប ដែលទំនងលោកជាមន្ត្រីរាជការមួយរូបដែរ ប៉ុន្តែសុំមិនបញ្ចេញអត្តសញ្ញាណបាននិយាយថា ជាទូទៅកម្មករ និងកម្មការនីមិនសូវជាចាប់អារម្មណ៍នឹងព័ត៌មាន ឬកិច្ចការប្រទេសជាតិអ្វីធំដុំទេ ។

លោកបញ្ជាក់ថា "មិនបាច់សួរពួកគាត់ច្រើនទេអូនអើយ ពួកគាត់មិនសូវតាមដានព័ត៌មានទេ"។

លោកបានបន្តទៀតថា ជាទូទៅបងប្អូនកម្មករ និងកម្មការនី គាត់ភាគច្រើនមិនសូវមានចំណេះអ្វីច្រើនទេ គឺមួយថ្ងៃៗ គឺគាត់គិតតែពីធ្វើការ ហើយនៅពេលទំនេរ គឺគាត់ច្រើនដើរលេងកំសាន្តមើលចម្រៀង មើលរឿង ។

លោកបានបញ្ជាក់ថា "សម្រាប់កម្មការនីភាគច្រើន បើសួររឿងច្បាប់រឿងអីមិនបាច់សួរពួកគាត់ទេ តែបើសួរគាត់អំពីរឿងកុន រឿងតារានេះ តារានោះ គឺគាត់ដឹងច្រើន ហើយប្រុសៗវិញ គឺសួររឿងផឹក រឿងសាច់ក្លែម អាផែនដីរស់ជាតិយ៉ាងម៉េច អាសាច់ជុំរស់ជាតិយ៉ាងម៉េច គឺគាត់ដឹង តែបើសួររឿងច្បាប់កុំសួរល្អជាង"។

លោកបានបន្តទៀតថា កន្លងមករឿងព័ត៌មាន ដែលគាត់ចង់ដឹងចង់ឮ គឺរឿងប្រាក់ខែ តែរឿងប្រទេសជាតិអ្វីមិនសូវប៉ុន្មានទេ ហើយការដែលគាត់ទៅបាតុកម្មទៅអីកន្លងមក គឺតាមសហជីព គឺជាអ្នកនាំ ។

ជុំវិញរឿងពង្រាងច្បាប់ អង្គការ សមាគម និងសហជីពអី លោកបានមានប្រសាសន៍ថា វាគឺជារឿងល្អ បើពួកគាត់ចេញតាមដាន ហើយរឿងនេះគឺវាពាក់ព័ន្ធជាមួយនឹងគាត់ដែរ ទោះមិនផ្ទាល់ជាមួយពួកគាត់ក៏ដោយ ។

លោកបានបញ្ជាក់ថា "ខ្ញុំចេះតែប្រាប់ឲ្យពួកគេរៀនស្ដាប់រៀនស្វែងយល់ពីព័ត៌មានដែរ ប៉ុន្តែភាគច្រើន មិនចាប់អារម្មណ៍ ទំនេរៗគាត់បើកតែប៉ុស្ដិ៍ដែលមានចម្រៀង និងកម្មសន្ទនាតាមទូរស័ព្ទ ពេលខ្លះថ្លង់ដេកមិនលក់ក៏មានដែរ"។

ក្រោយពេលដែលគណៈរដ្ឋមន្ត្រី បានប្រជុំអនុម័ត នូវសេចក្ដីព្រាងច្បាប់នេះកាលពីថ្ងៃទី ០៤ ខែ មិថុនា ឥឡូវសេចក្ដីព្រាងច្បាប់អង្គការ សមាគម និងសហជីពនេះបានធ្លាក់ដល់ដៃ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាហើយកាលពីថ្ងៃទី២៣ ។

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានរដ្ឋសភា បញ្ជូនទៅគណកម្មការជំនាញដើម្បីពិនិត្យ សិក្សាមុននឹងបញ្ចូលក្នុងរបៀបវារៈ នៃកិច្ចប្រជុំពេញអង្គរដ្ឋសភាពិភាក្សានិងអនុម័ត ។

ទាក់ទិននឹងសេចក្ដីព្រាងច្បាប់ដដែលនេះ នៅព្រឹកថ្ងៃទី ២៣ ខែ មិថុនាដដែល ក្រុមសកម្មជនអង្គការសង្គមស៊ីវិលជាច្រើននាក់ បានដើរហែក្បួនស្រែកតវ៉ាតាមផ្លូវ ចេញពីមុខរដ្ឋសភាដោយមិនមានការរារាំង ពីអាជ្ញាធរអ្វីឡើយ ។

បណ្ដាសកម្មជនទាំងនោះ បានស្នើរឲ្យរដ្ឋសភា ផ្អាកការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

នៅមុនពេលរៀបចំជាការតវ៉ាតាមផ្លូវសាធារណៈនេះ តំណាងអង្គការ សង្គមស៊ីវិលចំនួន១០ កាលពីថ្ងៃទី២២ ខែមិថុនា បានជួបជាមួយនឹងលោក សម រង្ស៊ី ប្រធានសភាភាគតិច និងជាប្រធានគណបក្សសង្គ្រោះជាតិ ។

នៅក្នុងជំនួបនោះ លោក សម រង្ស៊ី បានបង្ហាញជំហររបស់គណបក្សប្រឆាំងគឺដូចគ្នា នឹងជំហររបស់ក្រុមមេដឹកនាំអង្គការសង្គមស៊ីវិលដែរ មិនចង់ឲ្យមានច្បាប់ ស្ដីពីការគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាលឡើយ។

លោក សម រង្ស៊ី បានបញ្ជាក់ទៀតថា លោកនឹងប្រើប្រាស់ វប្បធម៌សន្ទនាពិភាក្សាជាមួយ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៅពេលខាងមុខនេះ។

*ដោយអរិយបុត្រ*

## ប្រធានព្រឹទ្ធសភាថ្មី ចាប់ផ្តើមការងារជាមួយនឹង ទីប្រឹក្សា ៣៨ រូប

សម្តេច សាយ ឈុំ ដែលត្រូវបានបោះឆ្នោតតែងតាំង ជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០៩ ខែមិថុនា ក្រោយការស្លាប់សម្តេច ជា ស៊ីម មួយថ្ងៃ កំពុងតែចាប់ផ្តើមការងារ ជាមួយនឹងទីប្រឹក្សាចំនួន ៣៨រូប ។

បន្ទាប់ពីបានទទួលតំណែង ជាប្រធានព្រឹទ្ធសភា កាលពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៥ ព្រះករុណាព្រះមហាក្សត្រ បានប្រោសព្រះរាជទាន ឡាយព្រះហត្ថលេខា លើព្រះរាជក្រឹត្យ តែងតាំងទីប្រឹក្សា ចំនួន ៣៨ រូប សម្រាប់ជួយកិច្ចការសម្តេច សាយ ឈុំ ។

ទីប្រឹក្សា ទាំង ៣៨ រូបរបស់សម្តេច សាយ ឈុំ មានឋានៈស្មើចាប់ពី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងឋានៈស្មើអគ្គនាយក។

ក្នុងព្រះរាជក្រឹត្យ ដែលផ្សព្វផ្សាយនៅព្រឹកថ្ងៃទី ២៤ ខែមិថុនានេះ ព្រះមហាក្សត្រ ក៏បានសម្រេចបញ្ចប់តំណែងទីប្រឹក្សា ជំនួយការ ព្រមទាំងនាយក នាយករង និងជំនួយការខុទ្ទកាល័យ សម្តេច ជាស៊ីម អតីតប្រធានព្រឹទ្ធសភា ដែលបានទទួលការតែងទាំង មុនថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥៕

# គណបក្សប្រជាជន ប្រកាសតំណែងថ្មី ដល់អ្នកដឹកនាំ

គណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយប្រធានមួយរូប អនុប្រធានមួយរូប និងប្រធានកិត្តិយសមួយរូបបានបង្កើតដំណែង អនុប្រធានថ្មីមួយកន្លែង កាលពីគណបក្សរៀបចំសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៨ អាណត្តិទី៥ កាលពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៥ ។

នៅក្នុងសន្និបាតនោះ សម្តេច ហ៊ុន សែន ត្រូវបានជ្រើសតាំង ជាប្រធានគណបក្ស ជំនួសសម្តេច ជា ស៊ីម ដែលទទួលមរណភាព ហើយបានជ្រើសតាំងអនុប្រធានពីររូប។

គណបក្សប្រជាជនកម្ពុជាបានប្រកាសថា អនុប្រធានទាំងពីររូបនេះ គឺមានសម្តេច សាយ ឈុំ និង សម្តេច ស ខេង ។

ការបោះឆ្នោតនេះ បានធ្វើឡើងនៅក្នុងចំណោមសមាជិក សមាជិកាគណៈកម្មាធិការកណ្តាលចំនួន ៥០៨រូប លើចំនួនសរុប៥៤៥រូប។

បន្ទាប់ពីការបោះឆ្នោត បានបញ្ចប់ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានមានប្រសាសន៍នៅក្នុង Facebook ផ្ទាល់ខ្លួនថា នៅក្នុងសន្និបាតនោះ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា សូមមន្ត្រីគណបក្សប្រជាជនកុំដេកស៊ីកេរ ៧មករា តែត្រូវសកម្ម លើកកម្ពស់ការបម្រើពិសេស បម្រើតម្រូវការរបស់ពលរដ្ឋដែលវិវត្តន៍តាមសម័យកាល ហើយមិនត្រូវពឹងកម្លាំងរបស់គេទេ សុខចិត្តឱ្យគេពឹងកម្លាំងយើងវិញ ៕

## ចិនប្រកាសយុទ្ធនាការ ប្រឆាំងជាថ្មី

ក្រោយពេលដែលចិន បានបើកយុទ្ធនាការបោសសំអាតអំពើពុករលួយអស់មួយចំនួន កាលពីពេលថ្មីៗកន្លងទៅកាលពីថ្ងៃទី២៤ ខែ មិថុនា អង្គភាពប្រឆាំងអំពើពុករលួយ នៃបក្សកុំម្មុយនីស្តចិនបានប្រកាសអំពីយុទ្ធនាការថ្មី។

អង្គភាពនេះ បាននិយាយថា ចិនដល់ពេលដំណើរការយុទ្ធនាការប្រឆាំងអំពើពុករលួយបន្តទៀតហើយ។

នៅក្នុងយុទ្ធនាការថ្មីនេះ អង្គភាព និង ក្រុមហ៊ុនរដ្ឋចំនួន ២៦ រួមទាំងកាសែតផ្លូវការ គឺកាសែត People's Daily របស់ចិន ក៏នឹងក្លាយជាមុខសញ្ញាត្រួតពិនិត្យការប្រព្រឹត្ត អំពើពុករលួយនេះផងដែរ។

នៅក្នុងចំណោមស្ថាប័ន ដែលស្ថិតនៅក្នុងបញ្ជីសើបអង្កេតថ្មី គឺ រួមមានក្រុមហ៊ុនអាកាសចរណ៍ ចិន អ៊ីស្ទើន អែឡាញ ក្រុមហ៊ុនដែកអាសាន អាយរុន អេនស្ទែល ក្រសួងគមនាគមន៍ និងរដ្ឋបាលអយស្ម័យានជាតិជាដើម៕

## វិភាគអន្តរជាតិ ៖ ផែនការអាមេរិកកំពុងតែដុតកំដៅនៃភាព តានតឹងជាមួយនឹងរុស្ស៊ី

អាមេរិកបានប្រកាស ពីផែនការដ៏ប្រកដប្រជាមួយ នៅក្នុងផែនការយុទ្ធសាស្ត្រយោធារបស់ខ្លួន នៅបណ្តាប្រទេសអឺរ៉ុបខាងកើត ដែលនាំឲ្យពិភពលោកកាន់តែប្រឈមមុខថែមទៀតនឹងកំណើនកំដៅ នៃភាពតានតឹងជាមួយនឹងរុស្ស៊ី។

អាស ខាតធី ( Ash Carter ) រដ្ឋមន្ត្រីការពារជាតិអាមេរិក បានអះអាងថា អាមេរិក នឹងដាក់ពង្រាយរថកោះ និងសំភារៈសិកទំនើបៗ ប្រមាណជា ២៥០ គ្រឿងនៅប្រទេស ចំនួន៦ ដែលជាអតីតរដ្ឋសហព័ន្ធ និង សម្ព័ន្ធមិត្តរបស់អតីតសហភាពសូវៀត។

ប្រទេសទាំង ៦ នេះ រួមមានដូចជាប្រទេសអេស្តូនី លីទុយអានី ឡាតវី ប៊ុលហ្គារី រ៉ូម៉ានី និងប៉ូឡូញ។

លោកបានអះអាងថា នេះគឺជាផែនការ ដើម្បីឆ្លើយតបនិងភាពឃោឃៅរបស់រុស្ស៊ី ហើយក៏ដើម្បីធានាដល់បណ្តាប្រទេសសមាជិកអង្គការអូតង់ ។

ឆ្លើយតបនឹងផែនការនេះ រដ្ឋាភិបាលក្រុងមូស្គូ បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំងក្លា ហើយថានឹងឆ្លើយតប នឹងការសំរេចចិត្តណាមួយ ដែលគំរាមកំហែងដល់សន្តិសុខរបស់សហព័ន្ធរុស្ស៊ីផងដែរ ។

អ្នកវិភាគបានឲ្យដឹងថា ទណ្ឌកម្មអាមេរិក និងសហគមន៍អឺរ៉ុប លើប្រទេសរុស្ស៊ី ប្រឆាំងនឹងការលុកលុយតំបន់គ្រីមេ គឺជាកំដៅនយោបាយមួយ ប៉ុន្តែបើអាមេរិកអនុវត្តផែនការ នៅអឺរ៉ុបខាងកើតទៀតនោះ រុស្ស៊ីកាន់តែក្រេវក្រោធ៕

## កម្ពុជាមានសម្តេចថ្មី២រូបបន្ថែមទៀតនៅឆ្នាំ២០១៥

នៅក្រោយពេលសម្តេច ជា ស៊ីម ប្រធានគណបក្សប្រជាជន និង ជាប្រធានព្រឹទ្ធសភា បានទទួលមរណភាពដោយជរាភាពនោះ ព្រះករុណា ព្រះមហាក្សត្របានប្រោសព្រះរាជទានគោរមងារជា "សម្តេច"ជូនឥស្សរជនកម្ពុជាពីររូប ។

តាមព្រះរាជក្រឹត្យ ដែលចុះព្រះហស្តលេខាដោយព្រះមហាក្សត្រ កាលពីថ្ងៃទី១៤ ខែ មិថុនា លោក ស ខេង ជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបានព្រះមហាក្សត្រប្រោសព្រះរាជទានគោរមងារជា "សម្តេចក្រឡាហោម ស ខេង" ដោយឡែកនៅក្នុងលោក សាយ ឈុំ ដែលជាប្រធានព្រឹទ្ធសភា ជំនួសសម្តេច ជា ស៊ីម ត្រូវបានទទួលគោរមងារជា "សម្តេចវិបុលសេនាភក្តី សាយ ឈុំ"។

ព្រះមហាក្សត្រ បានមានព្រះរាជបន្ទូល នៅក្នុងព្រះរាជក្រឹត្យនោះថា សម្តេចថ្មីទាំងពីរ គឺជាអ្នកដឹកនាំដ៏ឆ្នើមជាទីគោរពស្រឡាញ់ របស់ប្រជារាស្ត្របានជួយដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចូលរួមកសាងប្រព័ន្ធច្បាប់ សម្រាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ការអភិវឌ្ឍជាតិ គ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានកិច្ចសហប្រតិបត្តិការល្អ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី៕

# ពលរដ្ឋកម្ពុជាស្ទាក់ស្ទើរនៅក្នុងកា
# ពីប្រទេស

ក្រោយពេលដែល ជនភៀសខ្លួនចំនួន ៤ រូប ត្រូវបានអូស្ត្រាលីបញ្ជូនមកដល់ប្រទេសកម្ពុជា កាលពីដើមខែមិថុនាកន្លងទៅនេះ ពលរដ្ឋកម្ពុជាដែលជាម្ចាស់ផ្ទះ ហាក់ស្ទាក់ស្ទើរនៅក្នុងការនិយាយអំពីការទទួល ឬមិនទទួលពួកគេដោយសារតែមូលដ្ឋាន នៃសេដ្ឋកិច្ច និងមនុស្សធម៌។

លោក លី វាសនា អ្នកប្រកបរបរបើករ៉ឺម៉កម៉ូតូ (ទុក ទុក )បានអះអាងថា លោកបានដឹងអំពីព័ត៌មានថា កម្ពុជាជាប្រទេសមួយ ដែលស្ម័គ្រចិត្តទទួលជនភៀសខ្លួនពីអូស្ត្រាលីមក តាមរយៈកាសែត និងវិទ្យុ ។

លោក វាសនា ហាក់ដូចជាស្ទាក់ស្ទើរនៅក្នុងការនិយាយថា លោកផ្ទាល់មានអារម្មណ៍យ៉ាងម៉េច ចំពោះការដែលកម្ពុជាបើកទ្វារប្រទេស ទទួលយកជនភៀសខ្លួនទាំងនេះ មកកាន់ប្រទេស និងផលប៉ះពាល់សម្រាប់សង្គមផ្សេងៗ ។

លោកបានបញ្ជាក់ថា "ប្រសិនបើពួកគេ អាចរស់នៅក្នុងប្រទេសយើងបាននោះ យើងជាប្រជាជនសូមស្វាគមន៍ពួកគេ ពោលគឺយើងអាចនឹងរស់នៅទាំងអស់គ្នាបាន ទោះបីជានៅក្នុងពេលនេះ កម្ពុជាកំពុងតែមានប្រជាជនជាច្រើនដែលគ្មានការងារធ្វើក៏ដោយ"។

លោកបានបញ្ជាក់ថា "សម្រាប់ខ្ញុំផ្ទាល់ខ្ញុំយល់ថា ពួកគេ(ជនភៀសខ្លួនពីអូ-ស្ត្រាលី) ប្រហែលជាពិបាកនឹងរស់នៅក្នុងប្រទេសកម្ពុជាណាស់"។

លោកបានបន្តទៀតថា មកដល់ពេលនេះ មានប្រជាពលរដ្ឋកម្ពុជាជាច្រើនដែលគ្មានការងារធ្វើ ដូច្នេះតើពួកជនភៀសខ្លួនទាំងនោះនឹងធ្វើអ្វីទៅ ។

លោកបានបន្តទៀតថា "យើងជាម្ចាស់ប្រទេស យើងលំបាកនៅក្នុងការរកប្រាក់ហើយ ចុះទម្រាំប្រជាជាតិផ្សេងតើពួកគេលំបាកប៉ុណ្ណា ?"។

លោក វាសនា បានបន្តទៀតថា មកដល់ពេលនេះ កម្ពុជាយើងជាប្រទេសមួយដែលក្រីក្រ ប្រជាជនកម្ពុជាមួយចំនួន នៅមិនទាន់មានអ្វីហូបគ្រប់គ្រាន់ផង ខណៈដែលរដ្ឋាភិបាលវិញ គឺនៅមិនទាន់អាចដោះស្រាយបញ្ហាឬក៏ឆ្លើយតបនឹងបញ្ហានេះ បាននៅឡើយផងនោះ ចុះទម្រាំមានជនបរទេសមកថែមទៀត ។

ព្រាប រចនា ជាអាជីវករមួយរូបនៅផ្សារតាខ្មៅ បានឲ្យដឹងថា លោកស្រីក៏មិនជាមានបញ្ហាអ្វីនោះទេ ប្រសិនបើជនភៀសខ្លួនបរទេសទាំងនោះអាចនឹងមករស់នៅក្នុងប្រទេសកម្ពុជាបាននោះ ។

លោកស្រីបានបញ្ជាក់ថា "ប្រសិនបើពួកគេអាចរស់នៅជាមួយយើង (ប្រជា-ជននៅក្នុងស្រុក) បាន ដោយសុខសាន្ត វាគឺជារឿងអូខេ"។

ជុំវិញការមកដល់ របស់បណ្ដាជនភៀសខ្លួនទាំងនេះ លោកស្រីបានបង្ហាញអំពីការព្រួយបារម្ភខ្លះ អំពីសេចក្ដីសុខសុវត្ថិភាពសង្គមកម្ពុជា ដោយសារតែលោកស្រី បានទទួលព័ត៌មានមកថា បណ្ដាជនភៀសខ្លួន ដែលគេគ្រោងនឹងបញ្ជូនមកកកម្ពុជា គឺមានមកពីមជ្ឈឹមបូពារ ជាពិសេសគឺ អ៊ីរ៉ង់ និងកន្លែងដែលមកពីតំបន់ជម្លោះផ្សេងៗ។

លោកស្រីបានបញ្ជាក់ថា "យើងជាពលរដ្ឋគួរតែគិតអំពីចំណុច ព្រួយបារម្ភទាំងនេះផង"។

លោកស្រីបានបញ្ជាក់ទៀតថា "ពល-រដ្ឋកម្ពុជា យើងក៏ធ្លាប់ជាជនភៀសខ្លួនដែលព្យាយាម សុំសិទ្ធិរស់នៅប្រទេសផ្សេងៗផងដែរ ដូច្នេះប្រសិនបើ ប្រជាជាតិដ៏ទៃមកកម្ពុជា វាគឺជារឿងត្រឹមត្រូវហើយនេះ គឺជាសកម្មភាពមនុស្សធម៌នៅក្នុងនាមជាមនុស្សជាតិ"។

លោកស្រីបានបន្តទៀតថា សម្រាប់ខ្លួនលោកស្រីផ្ទាល់គឺលោកស្រីស្វាគមន៍ ប៉ុន្តែទន្ទឹមនឹងស្វាគមន៍ ក៏បារម្ភផងដែរ។



Photo by Khem Sovannara

" ជាគំនិតរបស់ខ្ញុំទេ ខ្ញុំស្វាគមន៍គ្រប់គ្នាមកកម្ពុជា ប៉ុន្តែខ្ញុំក៏មានទស្សនៈមួយទៀត គឺខ្ញុំមិនដឹងថា ប្រជាជនកម្ពុជាផ្សេងទៀតគេគិតនិងព្រួយបារម្ភ ដូចខ្ញុំឬក៏អត់នោះទ"។

លោក ជាញ់ សំរិទ្ធ ជាប្រជាពលរដ្ឋដែលមានឋានៈនៅក្នុងសង្គមមួយរូបបានឲ្យដឹងថា ដោយសារតែពលរដ្ឋកម្ពុជាយើងជាប្រទេសមួយដែលជ្រួតជ្រាបទៅនឹងសាសនា និងមនុស្សធម៌ លោកនិងប្រជាពលរដ្ឋដ៏ទៃទៀត គឺមិនជំទាស់នឹងការបើកទ្វារប្រទេសទទួលជនភៀសខ្លួនពីអូស្ត្រាលីទាំងនោះទេ ។

លោកបានបន្តទៀតថា តាមប្រវត្តិ-សាស្ត្រ ដែលលោកបានអានសៀវភៅប្រវត្តិសាស្ត្រ និងឯកសារខ្លះៗខ្មែរថ្មីត្បិតជាប្រទេសដែលអន់ខ្សោយ ក៏មិនដែលធ្លាប់ទទួលជនភៀសខ្លួននោះទេ ។

លោកបានបញ្ជាក់ថា "រឿងទទួលជនភៀសខ្លួនពីអូស្ត្រាលី គឺមិនមែនជាលើកទីមួយរបស់ខ្មែរទេ កន្លងមកខ្មែរគឺធ្លាប់ទទួលជនភៀសខ្លួនពីឡាវ ពីវៀត-ណាម ដូច្នេះបើយើងទទួលខ្លះទៀតក៏មិនជាអ្វីនោះដែរ ។ល ។"

## ទិដ្ឋភាពនៃការមកដល់នៃជនភៀសខ្លួនបួនរូប

ជនភៀសខ្លួនទាំងបួនរូបនេះត្រូវបានបញ្ជូនមកកម្ពុជាកាលពីថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១៥ ដែលមកដល់កម្ពុជាតាមជើង ហោះហើរម៉ាឡេស៊ីអែឡាញ ។

នៅមុនការមកដល់របស់ពួកគេ សន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញត្រូវបានរិតបន្តឹង ដូចនៅគ្រាដែលកម្ពុជាមាន គណប្រតិភូធ្វើដំណើរទៅក្រៅប្រទេស ឬ ត្រឡប់មកវិញដូច្នោះដែរ ដោយឡែកក្រុមអ្នកសារព័ត៌មានដែលបានតាមប្រមាញ់យក ព័ត៌មានពីពួកជនភៀសខ្លួនទាំង ៤ នាក់ នោះ មិនត្រូវបានអនុញ្ញាតឲ្យចូលទៅយកព័ត៌មាន ឬថតរូបឡើយ។ ក្រុមអ្នកសារព័ត៌មាន គឺបានត្រឹមតែអង្គុយរង់ចាំឆ្ងាយពីពួកគេតែប៉ុណ្ណោះ ។

មន្ត្រីអាជ្ញាធរកម្ពុជា បានឲ្យដឹងថា ពួកគេទាំងបួននាក់ដែលស្ម័គ្រចិត្តមករស់នៅកម្ពុជានេះ គឺមានជនជាតិអ៊ីរ៉ង់ (Iran) ៣នាក់ និង ម្នាក់ទៀតជាជនជាតិដើមភាគតិចរ៉ូហ៊ីងយ៉ា (Rohingya) ដែលរត់គេចខ្លួនពីប្រទេសមីយ៉ាន់ម៉ាឬភូមា។

មន្ត្រីបានអះអាងថា ពួកគេទាំងបួននាក់ ត្រូវបានគេផ្តល់កន្លែងស្នាក់នៅបណ្ដោះអាសន្នរួចហើយ គឺស្ថិតក្នុងសង្កាត់និរោធ ខណ្ឌច្បារអំពៅ បន្ទាប់ពីបញ្ជូនដល់ប្រទេសកម្ពុជាភ្លាមៗ ប៉ុន្តែទីតាំងពិតប្រាកដមិនត្រូវបានឲ្យដឹង។

# រទទួលឬមិនទទួលជនភៀសខ្លួន
# អូស្ត្រាលី

## សារតានៃការបញ្ជូនជនភៀសពីអូស្ត្រាលីមកកម្ពុជា

ការបញ្ជូននូវជនភៀសខ្លួនពីអូស្ត្រាលីមកកម្ពុជាគឺធ្វើឡើងតាមរយៈអនុស្សារណៈនៃការយោគយល់ គ្នាមួយ រវាងកម្ពុជា និងអូស្ត្រាលី ដែលបានចុះហត្ថលេខាកាលពីខែ កញ្ញា ឆ្នាំ២០១៤ កន្លងទៅ ។

អនុស្សារណៈ នៃការយោគយល់គ្នានោះ ត្រូវបានចុះ ដោយ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយនឹង លោក ស្កុត មូរីសុន ដែលជា រដ្ឋមន្ត្រីក្រសួងឥន្តោប្រវេសន៍និងការពារព្រំដែនអូស្ត្រាលី នៅក្នុងអំឡុងពេលលោកបានមកទស្សនៈកិច្ចនៅកម្ពុជា ។

នៅមុនពេល ចុះអនុស្សារណៈនេះលោកស្រី ជូលៀ អ៊ីសាបែល បីសូប រដ្ឋមន្រ្តីការបរទេសអូស្ត្រាលីបានធ្វើដំណើរមកបំពេញទស្សនៈកិច្ចនៅកម្ពុជា និងបានលើកសំណើរនេះទៅ សម្តេច តេជោ ហ៊ុន សែន នៅក្នុងជំនួបនៅវិមានសន្តិភាពកាលពីថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០១៤។

បន្ទាប់ពីសំណើរនោះ ភាគីកម្ពុជានិងអូស្ត្រាលីក៏បានពិភាក្សាគ្នាជាបន្តបន្ទាប់ រហូតបានសំរេចបាន នូវ អនុស្សារណៈខាងលើ ។

ជុំវិញបញ្ហានេះសម្តេចតេជោ ហ៊ុន សែន នៅក្នុងឋានៈជាប្រមុខរដ្ឋាភិបាល ធ្លាប់បានពន្យល់ សារធារណៈជន និង សរសេរលិខិតទៅកាន់សភាជាបន្តបន្ទាប់ថា នេះ គឺជាការសំរេចិត្តដើម្បី មនុស្សធម៌ ដោយសារតែកម្ពុជាគឺជាប្រទេសហត្ថលេខីមួយ នៃ អនុសញ្ញា ស្តីអំពីជនភៀសខ្លួនកាលពីឆ្នាំ១៩៥១ និង ពិធីសារឆ្នាំ១៩៦៧ពាក់ព័ន្ធនឹងជនភៀសខ្លួននេះ ហើយ កម្ពុជាក៏មានអនុក្រិត ដែល និយាយអំពីជនភៀសខ្លួននេះផងដែរ។

តាមរយៈ អនុស្សារណៈនេះ កម្ពុជាត្រូវបានគេដឹងថា គឺនឹងទទួលថវិការប្រមាណជា ៤០ លានដុល្លារពីអូស្ត្រាលីជាថ្នូរនឹងការទទួលយកជនភៀសខ្លួននេះ។



លោក សំរិទ្ធ គឺជាប្រជាពលរដ្ឋមួយរូប ដែលបង្ហាញអំពីគំនិតសុទិដ្ឋិនិយមចំពោះការទទួលបណ្តាជនភៀសខ្លួន ពីអូស្ត្រាលីទាំងនោះ ប៉ុន្តែលោកសុំរដ្ឋាភិបាល និងអាជ្ញាធរកម្ពុជាមួយ រឿងជនភៀសខ្លួនទាំងនេះ ។

លោកបានបញ្ជាក់ថា "ខ្ញុំមិនបញ្ហាទេ ហើយក៏មិនចង្អៀតចង្អល់ នៅក្នុងការចែកផែនដីមួយចំណែកតូចមួយ ដល់ជនភៀសខ្លួនទាំងនោះដែរ ប៉ុន្តែរដ្ឋាភិបាល និងអាជ្ញាធរ សុំកុំយកចិត្តទុកដាក់លើពួកគេឲ្យច្រើនលើសកំរិត យកចិត្តទុកដាក់ពលរដ្ឋម្ចាស់ស្រុក ទៅបានហើយ"។

លោកបានបញ្ជាក់ថា"កម្ពុជានៅមានពលរដ្ឋ ដែលរដ្ឋាភិបាល និងអាជ្ញាធរគួរតែយកចិត្តទុកដាក់សម្រាប់ ពួកគេច្រើន"។

លោក សេក ភក្តី ជាប្រជាពលរដ្ឋមួយរូប បានបន្តទៀតថា ជាទស្សនៈរបស់លោកតាំងពីដើមមក គឺមិនគាំទ្រឲ្យរដ្ឋាភិបាលបើកទ្វារប្រទេសទទួលជនភៀសខ្លួនពីអូស្ត្រាលីនេះទេ ប៉ុន្តែបើជ្រុលជាពួកគេ មកដល់ទៅហើយនោះ គឺមានតែឲ្យពួកគេចូលរួមចែករំលែកការលំបាកជាមួយគ្នា ។

លោកបានបញ្ជាក់ថា "តាមខ្ញុំគិត ខ្ញុំយល់ថា កម្ពុជាយើងពេលនេះ នៅមិនទាន់មានលទ្ធភាពទទួល ជនភៀសខ្លួនបានទេយើងនៅក្រណាស់"។

លោកបានបន្តទៀតថា ព័ត៌មានដែលនិយាយអំពីប្រជាពលរដ្ឋរងគ្រោះដោយការអត់ឃ្លាន រហូតដល់ថ្នាក់ជីកដំឡូងព្រៃមកបរិភោគ មានចុះនៅក្នុងព័ត៌មានជារឿយៗ អ្នកសុំទានទាំងចាស់ ទាំងក្មេងនៅតាមផ្លូវ តាមរមណីដ្ឋាននានាឡើងពេញ ពលករចំណាកស្រុករាប់សិបនាក់ទៅប្រទេសជិតខាង និងតំបន់គឺជាបញ្ហាបន្ទាន់ ដែលរដ្ឋាភិបាលគួរតែដោះស្រាយ ។

លោកបានសំដែង ការព្រួយបារម្ភបន្ថែមទៀតថា ចំពោះបញ្ហាដែលយើងបើកទ្វារ ទទួលជនភៀសខ្លួនទាំងនេះ លោកបានសំដែងយោបល់ថា ប្រសិនបើពួកគេស្ម័គ្រចិត្ត និងដាក់ចិត្តដាក់កាយរស់នៅជាមួយនឹង សង្គមកម្ពុជាយើងសុខទាំងអស់គ្នា នោះមិនសូវជាអ្វីនោះទេ ប៉ុន្តែចុះប្រសិនបើពួកគេ មកហើយគេមិនពេញចិត្តនឹងស្ថានភាព ដូចដែលគេរំពឹងទុក គេអុកឡុក គឺបង្កបញ្ហានេះបញ្ហានោះ តើយើងមិនឈឺក្បាលថែមមួយកំរិតទៀត។

លោកបានបញ្ជាក់ថា "យើងកំពុងតែឈឺស្រាប់ ចុះបើមកឈឺបន្ថែមទៀតតើយើងត្រូវគិតយ៉ាងម៉េច"។

លោក ទេព សង្ហា ជាប្រជាពលរដ្ឋមួយរូបដែរនោះ បានមានប្រសាសន៍ថា តាមអ្វីដែលរដ្ឋាភិបាល បានអះអាងថាការដែលកម្ពុជា សំរេចទទួលជនភៀសខ្លួនពីអូស្ត្រាលីមកនោះ គឺជារឿងមនុស្សធម៌ ប៉ុន្តែលោកបានបញ្ជាក់ថា នៅពេលនេះ មនុស្សធម៌នៅក្នុងលក្ខខណ្ឌបែបនេះគឺថា កម្ពុជាប្រហែលជាមិនទាន់មានលក្ខណៈសម្បត្តិ នៅក្នុងការអនុវត្តនៅឡើយទេ ដោយសារតែពេលនេះ កម្ពុជានៅតែជាប្រទេស ដែលមានឋានៈជាប្រទេសកំពុងតែអភិវឌ្ឍន៍ ភាពក្រីក្រនៅក្នុងប្រទេសគឺកំពុងតែមាន ហើយសេដ្ឋកិច្ច គឺកំពុងតែរើបៗ ហើយនៅតែជាប្រទេសដែលពឹងផ្អែកលើប្រាក់ជំនួយ ។

លោកបានបញ្ជាក់ថា "នេះគ្រាន់តែជាទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំទេ ប៉ុន្តែការដែលរដ្ឋាភិបាល លោកសំរេចទទួលប្រហែលជាគាត់មានជំហរអ្វីពិសេស និងមានហេតុផល ហើយបានជាសំរេចចិត្តបែបនេះ"។

លោកបានបញ្ជាក់ទៀតថា "រដ្ឋាភិបាលប្រហែលជាសម្លឹងឃើញអ្វីផ្សេង ពីការសំរេចចិត្តនេះ ជាមួយនឹងរដ្ឋាភិបាលអូស្ត្រាលីក៏មិនដឹង ពីព្រោះការសំរេចអ្វីមួយ ប្រហែលជាមិនអត់មានគោលដៅ និងគោលជំហរនោះទេ ពោលគឺថា មិនមែននៅសុខៗចេះតែយល់ព្រមនោះទេ"។

គួររំលឹកដែរថា កាលពីថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១៥នេះ ជនភៀសខ្លួនចំនួន ៤នាក់បានមកដល់ប្រទេសកម្ពុជា។ ពួកគេត្រូវបានរដ្ឋាភិបាល នៃប្រទេសអូស្ត្រាលី និងមន្ត្រីរដ្ឋាភិបាលកម្ពុជាបាន

# ទស្សនកិច្ចផ្លូវការរបស់លោកអភិបាល អូលីវីយេ នៅមណ្ឌលសកម្មភាពព្រះសីហនុ



ដដថដថ

លោកអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ដ្មឹតអឺស្លែរ បានបំពេញទស្សនកិច្ចជាផ្លូវការ ទៅកាន់មណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកព្រះសីហនុ ចាប់ពីថ្ងៃទី ១៧-២១ ខែមិថុនា។

ដំណើរទស្សនកិច្ចនេះ គឺជាពេលវេលាដែលលោកអភិបាល សួរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទ ស្តាប់នូវសេចក្តីរាយការផ្សេងៗ អំពីសកម្មភាពរបស់ព្រះសហគមន៍ ក្នុងការប្រកាសដំណឹងល្អ និងសម្តែងមេត្តាករុណា។ ស្វែងយល់ពីជីវភាពរបស់គ្រីស្តបរិស័ទ និងស្តាប់សំណូមពរនានា ពីគណៈកម្មការព្រះសហគមន៍ លោកបូជាចារ្យ ដូនជី យុវជន យុវនារី និង សេចក្តីត្រូវការរបស់ក្រុមកុមារជាដើម។

នៅថ្ងៃទី១៧លោកអភិបាលបានទៅសួរសុខទុក្ខគ្រីស្តបរិស័ទ នៅព្រះសហគមន៍ ត្រែងត្រយឹង ក្នុងខេត្តកំពង់ស្ពឺ។ ពេលរសៀល សួរសុខទុក្ខ និងថ្វាយអភិបូជា នៅព្រះសហគមន៍កាតូលិកក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង ពេលយប់សម្រាកនៅក្នុងព្រះវិហារតែម្តង។

ថ្ងៃទី១៨ ខែមិថុនា លោកបានបន្តដំណើរទៅជួបគ្រីស្តបរិស័ទ និងថ្វាយអភិបូជា នៅព្រះសហគមន៍ស្រែអំបិល ខេត្តកោះកុង និងបានទៅពិនិត្យការសាងសង់អគារ ព្រះវិហារ និងសាលាមត្តេយ្យក្នុងព្រះសហគមន៍នេះ ហើយបន្តដំណើរទៅខេត្តព្រះសីហនុ។ ក្នុងថ្ងៃនោះ ការធ្វើដំណើរដោយឡានឈ្នួលពីកោះកុងមកស្រែអំបិល និងពីស្រែអំបិលទៅក្រុងព្រះសីហនុ ព្រោះឡានរបស់លោក បានខូចនៅខេត្តកោះកុង មិនអាចជួសជុលបាន។

នៅថ្ងៃទី១៩ លោកបានទៅសួរសុខទុក្ខគ្រីស្តបរិស័ទ នៅបឹងតាព្រហ្ម និងថ្វាយអភិបូជានៅកោះខ្យង។ ពេលរសៀលសួរសុខទុក្ខ កុមារា កុមារី នៅសាលាមត្តេយ្យភូមិពុង៣ ស្រុកព្រៃនុប ខេត្តព្រះសីហនុ ហើយបន្តមកសួរសុខទុក្ខកុមារ នៅក្រុមបងស្រីគង្វាលដ៏សប្បុរស ព្រមទាំងពេលល្ងាច ទៅជួបក្រុមដូនជីដូមីនីកូ នៅខេត្តព្រះសីហនុ។



រូបថត: ?????

ថ្ងៃទី២០ មានការប្រជុំបូជាចារ្យ ក្នុងមណ្ឌលសកម្មភាព ប្រជុំជាមួយគណៈកម្មការព្រះសហគមន៍ទាំងអស់។ ណែនាំបេក្ខជន បេក្ខនារី ដែលរៀបចំខ្លួនទទួលអគ្គសញ្ញាលាបថ្វាស និងអធិដ្ឋានពេលយប់ជាមួយគេផងដែរ។

ថ្ងៃទី២០ ខែមិថុនា ២០១៥ មានអគ្គសញ្ញាលាបថ្វាស សម្រាប់មនុស្សពេញវ័យចំនួន ២៤រូប មកពីព្រះសហគមន៍នានា ក្នុងមណ្ឌលសកម្មភាពខេត្តព្រះសីហនុ។

នៅតាមកន្លែងនីមួយៗ តំណាងគ្រីស្តបរិស័ទ បានរាយការណ៍ជូនលោកអភិបាលអំពីប្រវត្តិព្រះសហគមន៍ សកម្មភាពលើកតម្កើងព្រះជាម្ចាស់ ការអប់រំបន្តជំនឿ កិច្ចការសង្គហៈជាដើម។ ជាងនេះ គេក៏មានជំរាបជូនលោកនូវបញ្ហាលំបាកមួយចំនួន និងបានលើកជាសំណូមពរជូនលោកផងដែរ។

ក្រោយពីបាន ទៅដល់កន្លែងនីមួយៗ ជាក់ស្តែង បានឃើញភាពជីវិត នៃព្រះសហគមន៍ និងស្តាប់ដោយយកចិត្តទុកដាក់ លោកអភិបាលអូលីវីយេ បានលើកទឹកចិត្តគ្រីស្តបរិស័ទ លោកបូជាចារ្យ និងបព្វជិត បព្វជិតា ក្នុងធម្មទេសនាបិទដំណើរទស្សនកិច្ច យ៉ាងនេះថា "សូមបងប្អូនថែរក្សាក្រុមគ្រីស្តបរិស័ទ" ។ លោកថា ទាំងអស់គ្នាមាន តួនាទីណែនាំគ្នាទៅវិញទៅមក ឲ្យយកចិត្តទុកដាក់អធិដ្ឋាន ឲ្យយកចិត្តទុកដាក់អប់រំជំនឿ និងទទួលការអប់រំជំនឿ។ ជំរុញឲ្យមានការសហការគ្នាយ៉ាងពិតប្រាកដ រវាងមនុស្សចាស់ និងយុវជន ដើម្បីកសាងព្រះសហគមន៍។ ជាងនេះទៅទៀត ធ្វើយ៉ាងណាណែនាំឲ្យក្រុមគ្រួសារនីមួយៗ ឲ្យមានការរីកចម្រើន ព្រោះគ្រួសារជាគោលព្រះសហគមន៍។

ចំពោះគ្រីស្តបរិស័ទ ដែលភាគច្រើនមិនបានមកវិហារ លោកអភិបាលលើកទឹកចិត្ត ដល់គ្រីស្តបរិស័ទដែលរឹងមាំក្នុងជំនឿឲ្យ "ចេញទៅ" សួរសុខទុក្ខគេលើកទឹកចិត្តគេ ណែនាំគេឲ្យយល់អំពីសារៈសំខាន់ក្នុងការនៅជាមួយព្រះយេស៊ូ និងត្រូវមានចិត្តអត់ធ្មត់ ជួយបងប្អូនទាំងនោះឲ្យយល់ពីជំនឿពិតប្រាកដ។

ក្នុងពេលនោះដែរ លោកអភិបាល លើកទឹកចិត្ត ឲ្យបងប្អូនបំពេញតួនាទីរបស់ខ្លួនជាគ្រីស្តបរិស័ទ ដែលជាបេសកកម្មសំខាន់បំផុត ក្នុងជីវិតជាគ្រីស្តបរិស័ទ ជាសាសនទូត គឺ"ប្រកាសដំណឹងល្អ"អំពីព្រះយេស៊ូ។ គឺប្រកាសអំពីវត្តមានរបស់ព្រះអង្គ ក្នុងរបៀបរស់នៅរបស់ខ្លួនប្រចាំថ្ងៃ តាមរយៈការចែករំលែកសេចក្តីស្រឡាញ់ ការបម្រើបងប្អូនក្រីក្រ អ្នកជំងឺ អ្នកតូចតាច អ្នកដែលគេមិនរាប់រក និងប្រកាសតាមរយៈទំនាក់ទំនងប្រចាំថ្ងៃរបស់យើងជាដើម ។

# ជីវិតចុងក្រោយពឹងលើព្រះជាម្ចាស់



រូបថតៈ?????

អ្នកស្រីផ្ទារ យូប្រាកដ កំពុងរស់នៅក្នុងផ្ទះថ្មធំល្មមមួយ ជាមួយលោកតាចំណាស់៧៩ឆ្នាំម្នាក់ ដែលគ្រីស្តបរិស័ទកាតូលិក បានស្គាល់គាត់ថា ជាអតីតអភិបាលនៃព្រះសហគមន៍កាតូលិក នៃភូមិភាគភ្នំពេញ ដើម្បីបម្រើ និងថែទាំលោកក្នុងពេលចូលនិវត្តន៍។

អ្នកស្រីយូប្រាកដមានវ័យ៦៤ឆ្នាំបានមករស់នៅផ្ទះ សម្រាប់លោកអភិបាលចូលនិវត្តន៍នេះ អស់ជិត៥ឆ្នាំហើយ។ អ្នកស្រី បានមានប្រសាសន៍ថា ការងារនៅទីនេះជាការពេញចិត្តរបស់គាត់ ។ សម្រាប់អ្នកស្រីការមករស់នៅទីនេះ "គឺមានអត្ថន័យណាស់សម្រាប់ខ្ញុំ។ ប្រៀបដូចខ្ញុំបានរកឃើញកំណប់ដ៏មហាសាលដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យ គឺលោកអភិបាល អេមីល ជាព្រះយេស៊ូផ្ទាល់"។

ក្រោយពីចូលនិវត្តន៍ពីស្ថាបនរដ្ឋក្នុងឆ្នាំ២០១០ អ្នកស្រីផ្ទារ យូប្រាកដ បានចូលបម្រើកិច្ចការងារព្រះសហគមន៍ និងក្រោយមកជាលេខាធិការិនី របស់លោកអភិបាលអេមីល ដេតម្ប។

នៅពេលដែលលោកអភិបាល អេមីល ចូលនិវត្តន៍ក្នុងឆ្នាំ២០១០ អ្នកស្រីបានសម្រេចចិត្ត នៅមើលថែរក្សាគាត់ព្រោះជារឿយៗ អ្នកស្រីធ្លាប់ឮលោកអភិបាលពោលថា "ពិតមែនហើយ ម្ដាយខ្ញុំជាជនជាតិបារាំងដូច្នេះខ្ញុំក៏ជាតិបារាំងមានច្រមុះស្រួច មិនអាចផ្លាស់ប្ដូរបានទេ ប៉ុន្តែបេះដូងខ្ញុំជាបេះដូងខ្មែរ ខ្ញុំមិនចង់ទៅបារាំងវិញទេ"។ អ្នកស្រីរំឭកទៀតថា លោកបូជាចារ្យម្នាក់បានប្រាប់គាត់ថាលោកអភិបាលសុំនៅស្រុកខ្មែរសុំកប់នៅដីខ្មែរ ដោយឲ្យរូបកាយគាត់រលាយទៅជាដីខ្មែរ។

អ្នកស្រីបាននិយាយ ទាំងអួលដើមករថា ពាក្យសំដីទាំងនេះបានដក់ជាប់ក្នុងចិត្តរបស់អ្នកស្រីរហូតមក។ ហើយជំនឿដែលអ្នកស្រីបានទទួលគឺបានមកពីព្រះសហគមន៍ និងដោយការខិតខំប្រមែរប្រមូលគ្រីស្តបរិស័ទឡើងវិញ របស់លោកអភិបាលក្នុងឆ្នាំ១៩៩០។

អ្នកស្រី ប្រាកដពោលថា អ្នកស្រីសូមអរគុណព្រះជាម្ចាស់ ចំពោះព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ដែលបានត្រាស់ហៅគាត់ជាឧបករណ៍ថែរក្សាលោក អេមីល និងអរគុណលោកអភិបាលអូលីវីយេ និងក្រុមសាសនទូតទីក្រុងបារីស ដែលបានឲ្យគាត់បម្រើនៅក្នុងផ្ទះលោកអភិបាលចូលនិវត្តន៍នេះ។

ជារៀងរាល់ថ្ងៃ អ្នកស្រីតែងតែក្រោកពីព្រលឹម ដើម្បីរៀបចំអាហារពេលព្រឹករំពេកកាលវិភាគប្រចាំថ្ងៃជូនអតីតអភិបាល និងចូលរួមអភិបូជាជាមួយលោក។

អ្នកស្រីនិយាយបែបលេងសើចបន្តិចដែរថា អ្នកស្រីហាក់ដូចជាមានសំណាងជាងក្រុមបងស្រីឯទៀតៗ ដោយសាររាល់ថ្ងៃ គាត់បានចូលរួមថ្វាយអភិបូជាគ្មានលោះឡើយជាមួយលោកអភិបាលអេមីល គឺនៅជិតស្និទ្ធនឹងព្រះជាម្ចាស់ក្នុងការអធិដ្ឋាន និងការសរសើរតម្កើងព្រះជាម្ចាស់។

អង្គុយលើកៅអីក្នុងបន្ទប់អាហារ ភ្នែករំពៃរកមើលលោកអភិបាល អេមីល ផងអ្នកស្រីបានបន្ថែមទៀតថាមនុស្សចាស់ដែលមានជំងឺ តែងប្រែប្រួលអត់ទៀងទេពេលខ្លះ គាត់អត់ដឹងថាយប់ឬថ្ងៃផង។ ដូច្នេះអ្នកស្រី ត្រូវរៀនពីគាត់ពីមួយថ្ងៃទៅមួយថ្ងៃ។ អ្នកស្រីប្រាកដ "បើថាឲ្យខ្ញុំស្គាល់គាត់ច្បាស់គឺអត់ទេ"។

អ្នកស្រីផ្ទារ យូប្រាកដ ជាកូនទី៧នៅក្នុងចំណោមគ្រួសារគ្រីស្តបរិស័ទ ដែលមានកូន៨នាក់ ដែលមានឪពុក ជាកម្មកររោងពុម្ព និងម្ដាយជាមេផ្ទះ និងមានបងប្រុស២នាក់ បានបួសជាបូជា-ចារ្យកាតូលិក ដែលម្នាក់ជាអតីតអភិ-បាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញពីដើម។ អ្នកស្រីបានរំឭកថា

## សន្ត ថូម៉ាស ម៉ូរ



លោកថូម៉ាសម៉ូរ រៀននៅទីក្រុងឡុងនៃប្រទេសអង់គ្លេស។ កាលនៅក្មេង លោកជួយបម្រើ លោកអភិបាលព្រះសហគមន៍។ ក្រោយមក លោកទៅរៀនច្បាប់នៅសកលវិទ្យាល័យ និងរៀបការ។ ថ្ងៃមួយ ពេលភរិយារបស់លោកទទួលមរណភាពទៅ លោកក៏រៀបការភរិយាថ្មីមួយទៀត ដើម្បីជួយអប់រំកូនទាំងបួនរបស់លោក។ ក្រុមគ្រួសាររបស់លោករស់នៅជាមួយគ្នាប្រកបដោយសុភមង្គលទាំងចែកទ្រព្យសម្បត្តិ ដល់ជនក្រីក្រផង។ សម័យនោះ ស្តេចហង់រីទី៨ បានតែងតាំងលោក ឲ្យធ្វើជានាយករដ្ឋមន្ត្រីនៅប្រទេសអង់គ្លេស។ លោកថូម៉ាស តែងជួយការពារអ្នកក្រីក្រ ពីភាពអយុត្តិ-ធម៌ជានិច្ច លោកប្រឆាំងនឹងអស់អ្នកមុខអ្នកការណាដែលបំពានច្បាប់។ លោកមិនខ្លាចពួកគេទាល់តែសោះ។

ថ្ងៃមួយ ពេលដែលលោកកំពុងចូលរួមថ្វាយអភិបូជាដូចធម្មតា ស្រាប់តែមានលិខិតពីស្តេច បង្គាប់ឲ្យលោកទៅគាល់ព្រះអង្គ។ លោកមិនចាកចេញពីព្រះវិហារភ្លាមៗនោះទេ លុះត្រាតែអភិបូជាចប់។ លោកផ្ដាំតាមអ្នកកាន់សំបុត្រនោះឲ្យទៅទូលស្តេចថា ទាល់តែលោកជួបជាមួយស្តេចនៃ ស្ថានបរមសុខចប់សិន ទើបលោកទៅជួបនឹងស្តេចនៃផែនដី។

សម័យនោះ ស្តេចហង់រី ចង់ឲ្យមានច្បាប់មួយបន្ថែមទៀត តែងតាំងព្រះអង្គ ឲ្យទៅជាមេដឹកនាំព្រះសហគមន៍នៅក្នុងប្រទេសអង់គ្លេស ជំនួសសម្តេចប៉ាប ដែលជាអ្នកដឹកនាំព្រះសហគមន៍ និង ដែលជាអ្នកមិនព្រមអនុញ្ញាតឲ្យទ្រង់លែងលះពីព្រះមហេសី។ ថូម៉ាស ម៉ូរ មិនព្រមធ្វើតាមព្រះបញ្ជារបស់ស្តេចទេ លោកសុខចិត្តលាលែងពីតំណែង ហើយក្រោយមកគេចាប់លោកដាក់ក្នុងគុក។ នៅក្នុងគុក លោករងទុក្ខលំបាកគ្រប់បែបយ៉ាង ដោយសារលោកប្រព្រឹត្តតាមអំពើសុចរិត។ នៅឆ្នាំ១៥៣៥ មុននឹងគេកាត់កប្រហារជីវិតលោក លោកអធិដ្ឋានអង្វរព្រះជាម្ចាស់ សម្រាប់ស្តេចហង់រីទី៨៕

# បុណ្យរុងរឿងសច្ចាទទួលតួនាទីជាគ្រីស្តបរិស័ទមួយជីវិត







*រូបថត: លី សុវណ្ណា*

យុវជន-នារី ចំនួន២០នាក់ ក្នុងសម្លៀកបំពាក់ពណ៌ស ដោយដៃកាន់ទៀនពណ៌សមួយផង បានដើរដង្ហែ ជាពីរជួរក្នុងក្បួនចូលពិធីអភិបូជា ដើម្បីទទួលបុណ្យរុងរឿងដែលទើបតែរៀបចំសារជាថ្មីម្តងទៀតនៅក្នុងព្រះសហគមន៍បាត់ដំបងក្រុង កាលពីថ្ងៃទី២៨ មិថុនា កន្លងទៅនេះ ក្រោមអធិបតីភាពរបស់លោក ហ្វីការេដូ គីគេ ជាអភិបាលព្រះសហគមន៍ កាតូលិកភូមិភាគ បាត់-ដំបង ចូលរួមដោយលោកបូជាចារ្យ និងគ្រីស្តបរិស័ទជាច្រើននាក់។

ពិធីបុណ្យរុងរឿង គឺជាបុណ្យមួយពីដូនតាគ្រីស្តបរិស័ទ នៅក្នុងភូមិភាគបាត់ដំបង ដែលបានបន្សល់ទុកជាយូរណាស់មកហើយ ហើយត្រូវបានបាត់បង់ក្នុងពេលកម្ពុជា មានសង្គ្រាមស៊ីវិល។ នេះជាលើកទី១ហើយ ដែលព្រះសហគមន៍នេះ បានរៀបចំឲ្យមានជាលើកដំបូងម្តងទៀត។ លោកតូតែត បាណេណាល់ ជាបូជាចារ្យទទួលខុសត្រូវនៅព្រះវិហារ ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ បានមានប្រសាសន៍ថា "បុណ្យរុងរឿងជាបុណ្យប្រពៃណីមួយរបស់គ្រីស្តបរិស័ទ នៅទីនេះ។ តែដោយសារសង្គ្រាមយើងបាត់បង់កម្មវិធីនេះ។ បុណ្យនេះគឺធ្វើឡើងដើម្បីឲ្យគ្រីស្តបរិស័ទ ទទួលស្គាល់ជំនឿរបស់ខ្លួននិងសន្យាធ្វើជាសក្ខីភាពនៃជំនឿរហូតដល់ចុងបញ្ចប់ នៃជីវិតរបស់ពួកគាត់"។

លោកបូជាចារ្យ តូតែត បានបញ្ជាក់ទៀតថា បុណ្យនេះ គ្រីស្តបរិស័ទចង់ទទួលក៏បាន អត់ក៏បាន ព្រោះវាមិនមែនជាអគ្គសញ្ញាទេ។ តែវាគឺជាពិធីមួយធ្វើឡើងបន្ទាប់ពីអគ្គសញ្ញាលាបថ្ងាស។

មុនពេលគ្រីស្តបរិស័ទទទួលពិធីនេះ លោកបូជាចារ្យឲ្យដឹងថា គ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាលាបថ្ងាស ត្រូវរៀនអប់រំជំនឿចំនួន៣ឆ្នាំបន្ថែមទៀត។ លោកបន្តថាឥឡូវពិធីនេះ មានតែគ្រីស្តបរិស័ទ ដែលបានទទួលពិធីជ្រមុជទឹកកាលពីនៅតូចៗដែលទទួល តែលោកនឹងរៀបចំឲ្យមានគ្រីស្តបរិស័ទ ដែលផ្លាស់ប្តូរមកកាតូលិកបានទទួលពិធីនេះដែរ។

លោកបូជាចារ្យបានបញ្ជាក់ថា ព្រះសហគមន៍បាត់ដំបងទើបនឹងរៀបចំកម្មវិធីនេះឡើង ដោយសារតែក្នុងរយៈពេល ៥-៦ឆ្នាំនេះ ព្រះសហគមន៍នេះបានរៀបចំឲ្យមានប្រព័ន្ធអប់រំជំនឿ ដោយមានដំណាក់កាលមេរៀន និងពិធីផ្សេងៗជាក់លាក់និងច្បាស់លាស់ហើយ។

នៅក្នុងពិធីបុណ្យ រុងរឿងនោះ យុវ-ជន-នារីទាំង២០នាក់ បានឡើងម្តង២នាក់ៗ ដោយដៃម្ខាងកាន់ទៀន និងដៃម្ខាងទៀត ដាក់ទ្រាបលើព្រះគម្ពីរ ដែលបានដាក់នៅចំពីមុខអាសនៈ មុខលោកបូជាចារ្យ និងលោកអភិបាល និងនៅមុខគ្រីស្តបរិស័ទ ប្រមាណជាង ២០០នាក់ធ្វើពាក្យសច្ចារបស់ខ្លួនយ៉ាងនេះថា " កូនសូមប្តេជ្ញា នឹងកាន់ជំនឿឲ្យបានមាំមួន និងប្រកាសជំនឿនេះរហូតដល់ចុងបញ្ចប់នៃជីវិតរបស់កូន"។

យុវតី សុខ ចាន់ អាយុ២៤ឆ្នាំបាន និយាយថា "ពាក្យសច្ចានេះគឺជាការកាន់ភ្ជាប់ថាយើងម្នាក់ៗ ជាគ្រីស្តបរិស័ទ។ បញ្ជាក់ថាថ្ងៃក្រោយ យើងអត់លះបង់ជំនឿរបស់យើងទេ ដល់យើងស្លាប់។ ពេលហ្នឹងភ័យខ្លាំង ហើយរំភើប និងចង់យំផង ព្រោះមានទាំងពិធីសច្ចាផង និងសុំទោសឪពុកម្តាយផង"។

សុខ ចាន់ បានឲ្យដឹងទៀតថា មុនពេលនាងទទួលបុណ្យរុងរឿងនេះ នាងត្រូវរៀនចំនួន៣ឆ្នាំ គឺរៀនអំពីគម្ពីរព្យា-ការី គម្ពីរពង្សសាវតាក្សត្រ គម្ពីរដំណឹងល្អព្រះសហគមន៍ និងអគ្គសញ្ញាទាំង៧ ។

អ្នកស្រីហែម បូរី ជាគ្រីស្តបរិស័ទតាំងពីកុមារ ហើយធ្លាប់បានទទួលពិធីបុណ្យរុងរឿងនេះ តាំងពីវ័យជំទង់មក មានប្រសាសន៍ថា "ពេលនៅតូច ខ្ញុំត្រូវបានឪពុកម្តាយយកទៅជ្រមុជទឹកដោយមានឪពុកម្តាយធម៌ជាអ្នកធ្វើពាក្យសច្ចាជំនួស។ ប៉ុន្តែដល់ពេលធំយើងទៅរៀនអប់រំជំនឿ ទទួល(អគ្គសញ្ញា)ព្រះកាយទទួលអគ្គសញ្ញាលាបថ្ងាស មានន័យថាយើងពេញវ័យក្នុងជំនឿហើយ។ ហើយបុណ្យរុងរឿងហ្នឹង គឺយើងសច្ចាដោយខ្លួនយើង ដោយមិនបាច់នរណាបញ្ជាក់ឲ្យយើងទៀតទេ ដោយសច្ចារស់នៅតាមក្រឹត្យវិន័យរបស់ព្រះអង្គ ដោយទៀងត្រង់រហូតដល់ស្លាប់"។

រំលឹកអំពីពាក្យសច្ចានេះ អ្នកស្រីបានបន្ថែមថា គ្រប់ពេលវេលាពាក្យសច្ចានេះបានជួយដាស់តឿន និង រំលឹកជំនឿរបស់អ្នកស្រីក្នុងជីវិតរស់នៅ មិនថាក្នុងទុក្ខវេទនាឬអំណរសប្បាយទេ។ អ្នកស្រីបូរី "នៅពេលដែលយើងធ្វើអ្វីដែលខុសយើងនឹកឃើញថា អញសច្ចាហើយ ត្រូវតែចងចាំនិងរំលឹកឡើងវិញ"។ តាមរយៈជំនឿនិងការអធិដ្ឋាន អ្នកស្រីបញ្ជាក់ថាក្នុងសម័យប៉ុលពត ព្រះជាម្ចាស់បានប្រទានឲ្យគាត់ មានកំលាំងធ្វើការខណៈពេលគាត់គ្មានអាហារហូបឆ្អែត ហើយព្រះអង្គ ក៏បង្អុរទឹកភ្លៀងពេលរាំងស្ងួតដែរ។

លោកអភិបាល គីគេ បានមានប្រសាសន៍ថា ពិធីនេះលើកទឹកចិត្តដល់គ្រីស្តបរិស័ទច្រើនដោយសារយើងរំលឹកជំនឿ អគ្គសញ្ញាដែលយើងបានទទួល និងឲ្យយើងទទួលតួនាទីថា យើងជាគ្រីស្តបរិស័ទអស់មួយជីវិត សម្រាប់ធ្វើជាសាក្សីចំពោះជំនឿដែលយើងមាន ។ លោកអភិបាលបន្តថា "ខ្ញុំឃើញថា នៅបាត់ដំបង មានការលើកទឹកចិត្តច្រើនពីក្រុមគ្រួសារ ដែលឪពុកម្តាយសប្បាយចិត្តជាមួយកូន ហើយកូនសប្បាយចិត្តជាមួយឪពុកម្តាយ។ មានអត្ថន័យថាជំនឿបានចូលក្នុងដួងចិត្ត ឲ្យពេញចិត្ត និង មានកំលាំងដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់"។

លោកអភិបាលមានប្រសាសន៍ទៀតថា លោកនឹងខិតខំណែនាំព្រះសហ-គមន៍នានា ឲ្យយល់អំពីអត្ថន័យ នៃបុណ្យរុងរឿងនេះ ដោយសារ នេះជាប្រពៃណីមួយ របស់ព្រះសហគមន៍ក្នុងភូមិភាគនេះ។ លោកអភិបាល "យើងនឹងចែកបទពិសោធន៍ ដែលយើងមានហើយបើព្រះសហគមន៍ដទៃ ទទួលយើងសប្បាយ បើអត់ទទួល(ក៏មិនអី) ដោយយើងមានអគ្គសញ្ញា នៅព្រះសហគមន៍ល្អហើយ តែបើយើងថែមដោយសារប្រពៃណីយើង ខ្ញុំគិតថាល្អដែរ"។

ព្រះសហគមន៍បាត់ដំបងក្រុង មានមានចំណាស់ ២២៥ឆ្នាំមកហើយ ។ ហើយព្រះសហគមន៍នេះ មានប្រពៃណីពីបុរាណជាច្រើនផងដែរ ដែលគ្រីស្តបរិស័ទ តែងតែប្រកាន់ខ្ជាប់រហូតមកដល់ពេលនេះ ដូចជាបុណ្យហែព្រះនាងម៉ារី(ជាម្តាយព្រះយេស៊ូ) ធម៌សូត្រពីបុរាណជាភាសាខ្មែរសម្រាយ និងពិធីបុណ្យរុងរឿងនេះ៕

*ដោយ????*

# ព្រះវិហារគ្រួសារដ៏វិសុទ្ធនៅអ្នកលឿង
# បើកសម្ពោធជាផ្លូវការ



*លោកអភិបាលអូលីវីយេចូលរួមសម្ពោធព្រះវិហារនៅអ្នកលឿង ។ រូបថត: សុធីរិទ្ធិ*

ព្រះវិហារថ្មីមួយខ្នង ដ៏ស្រស់ស្អាត ធ្វើពីបេតុង មានបណ្ដោយ ៥៣.២ម៉ែត្រ និងទទឹង ១៤.១៥ម៉ែត្រ ដែលសាងសង់រួចរាល់ បានប្រារព្ធពិធីបាចទឹកព្រះពរ និង សម្ពោធជាផ្លូវការដាក់ឲ្យប្រើប្រាស់ កាលពីថ្ងៃទី ១២ មិថុនា ២០១៥ កន្លងទៅ។ ពិធីនេះមានការអញ្ជើញចូលរួមជាអធិបតីពីសំណាក់លោក អូលីវីយេ ផ្មីតអីស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកអន់តូនីសាមី ស៊ូសៃរាជ ជាអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម និងចូលរួមជាកិត្តិយស ពីសំណាក់លោកបូជាចារ្យ បព្វជិត បព្វជិតា និងគ្រីស្តបរិស័ទចំនួនប្រមាណជា ៦០០ នាក់ ក្នុងនោះ មានតំណាងមកពីព្រះសហគមន៍ភូមិភាគបាត់ដំបង និងភ្នំពេញផងដែរ។

ព្រះវិហារថ្មីនេះមានឈ្មោះថា "ព្រះវិហារគ្រួសារដ៏វិសុទ្ធ" ស្ថិតនៅភូមិទី៦ (អ្នកលឿង) ឃុំព្រែកខ្សាយ"ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង នៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ។

ពេលចាប់ផ្តើមពិធី គឺមានដង្ហែរូបសំណាកគ្រួសារដ៏វិសុទ្ធ ជុំវិញភូមិគ្រីស្តបរិស័ទ ដែលនាំមុខដោយក្រុមម៉ុងសាយតាមប្រពៃណីរបស់ជនជាតិ វៀតណាម និងបន្ទរដោយបទចំរៀង លើកតម្កើងព្រះជាម្ចាស់ ឆ្ពោះទៅចូលក្នុងព្រះវិហារថ្មី។ គ្រីស្តបរិស័ទទាំងអស់បានចូលរួមក្នុងក្បួននេះ ប្រកបដោយទឹកមុខសប្បាយរីករាយ។

នៅក្នុងធម្មទេសនា លោក អូលីវីយេ បានមានប្រសាសន៍ថា៖ យើងសប្បាយរីករាយ ដោយទទួលបានព្រះវិហារថ្មី។ ព្រះវិហារ ជាកន្លែងជួបជុំគ្នា ដើម្បីអធិដ្ឋានស្វាមស្វាត់ មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ស្តាប់ព្រះបន្ទូលនិងជាកន្លែងចិញ្ចឹមជំនឿរបស់យើង ហើយជាងនេះទៅទៀត ព្រះវិហារ ជាកន្លែងដែលផ្តល់អត្តសញ្ញាណនានាក្នុងព្រះសហគមន៍ ហើយក៏ជាកន្លែងមួយ ដែលណែនាំយើងឲ្យទៅជាមនុស្សវិសុទ្ធដែរ ។

លោកបានបន្ថែមថា៖ ព្រះវិហារគឺជាព្រះតំណាក់ដែលព្រះជាម្ចាស់ គង់នៅ ជាកន្លែងសក្ការៈ យើងត្រូវចេញចូលទាក់ទងជាមួយព្រះអង្គ។ លោកអភិបាលក៏បានបញ្ជាក់រំលឹក ដល់គ្រីស្តបរិស័ទឲ្យបំពេញតួនាទីរបស់ខ្លួនជាថ្មីដែលមានជីវិត សម្រាប់កសាងព្រះសហគមន៍ឲ្យរឹងមាំ។

ចំណែកលោកអភិបាល អន់តូនី ជាអភិបាល ប្រចាំព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ក៏បានមានមានប្រសាសន៍ក្នុងពិធីនេះដែរថា៖ យើងទាំងអស់គ្នាមានអំណរសប្បាយ ដោយទទួលសមិត្តិផលព្រះវិហារថ្មីនៅអ្នកលឿង និងមានបងប្អូនជាច្រើន ដែលមកពីទាំងបីភូមិភាគមកចូលរួម ដើម្បីលើកទឹកចិត្តដល់បងប្អូននៅ ព្រះសហគមន៏កាតូលិកនៅទីនេះ។ លោកបន្តរំលឹកថាកាលពីមុន លោកមានសេចក្តីព្រួយបារម្ភ ដោយសារបងប្អូនគ្រីស្តបរិស័ទ នៅអ្នកលឿងមានចំនួនច្រើន គឺមានចំនួនប្រមាណជាង ១០០០នាក់ ហើយព្រះសហគមន៍មានទីកន្លែងតូច។ម្យ៉ាងពួកគេមិនសូវជាបើកចិត្ត ទទួលបងប្អូនខ្មែរប៉ុន្មានដែរ តែបន្តិចម្តងៗ លោកឡាយប៉ូល ជាបូជាចារ្យទទួលខុសត្រូវ បានបើកសាលាមត្តេយ្យ និងថ្នាក់អក្ខរកម្មភាសាខ្មែរដល់គេ ហើយបានបង្រៀនអំពីការរស់នៅរបៀបជាខ្មែរ។ លោកបន្តទៀតថា៖ គ្រីស្តបរិស័ទទីនេះ គេមានជំនឿរឹងមាំ ពួកគេរួបរួមគ្នាកសាងព្រះ-វិហារ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រះសហគមន៍កាតូលិកនៅអ្នកលឿង មានរបៀបលក្ខណៈជាខ្មែរច្រើន ជាក់ស្តែងដូចជាការតុបតែងព្រះវិហារ ដោយការដាក់រូបសំណាក់ ឬរូបថតផ្សេងៗ អំពីព្រះយេស៊ូគឺមានលក្ខណៈជាខ្មែរ។

លោកបានបង្ហាញ នូវគំនិតប្រកបដោយសុទិដ្ឋិនិយមថា៖ "នៅថ្ងៃអនាគត ខ្ញុំសង្ឃឹមថា ព្រះសហគមន៍កាតូលិកនៅអ្នកលឿងនេះនឹងមានការរីកចម្រើន ដោយមិនប្រកាន់ជាតិសាសន៍ គឺរួបរួមគ្នាក្នុងមហាគ្រួសារតែមួយ"។

ព្រះវិហារ (គ្រួសារដ៏វិសុទ្ធ) នៃព្រះសហគមន៍អ្នកលឿង ត្រូវបានបង្កើតឡើងក្នុងអំឡុងឆ្នាំ ១៨៦៤ ដែលមានឈ្មោះដើមថា "បាណាម" គឺនៅពាមរក៍បច្ចុប្បន្ន ដោយលោកបូជាចារ្យជាតិបារាំងម្នាក់ឈ្មោះ "PIANET"។ ក្នុងឆ្នាំ១៩៧០ ព្រះវិហារបាណាម ត្រូវបានកំទេចទាំងស្រុង ដោយគ្រាប់បែកសហ-រដ្ឋអាមេរិក។ នៅក្នុងសម័យសង្គ្រាម ១៩៧៥ - ១៩៧៦ គ្មានគ្រីស្តបរិស័ទ។ ចាប់ពីឆ្នាំ ១៩៨៤ គ្រីស្តបរិស័ទបានជួបជុំគ្នាដោយលួចលាក់តាមផ្ទះ។ គេអធិដ្ឋាន អភិបូជា និងទទួល អគ្គសញ្ញាផ្សេងៗ ម្តងម្កាលជាមួយបូជាចារ្យដែលមកសួរសុខទុក្ខគេ។ ពីឆ្នាំ២០០០ រហូតដល់បច្ចុបន្បនេះ គឺមានលោកអភិបាលអន់តូនី ទទួលខុសត្រូវជាអភិបាលភូមិភាគ ហើយក្នុងកំឡុងពេលនោះព្រះសហគមន៍អ្នកលឿង មានព្រះវិហារមួយគឺជញ្ជាំងថ្ម តំបូលប្រក់ស័ង្គសី។

លោក ឡាយប៉ូល ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍អ្នកលឿង បានឲ្យដឹងថា៖ មានរឿងរ៉ាវជាច្រើនដែលទាក់ទងទៅនឹងព្រះសហគមន៍អ្នកលឿង តែអ្វីដែលសំខាន់ គឺពេលនេះយើងទាំងអស់គ្នាសប្បាយចិត្ត ដោយទទួលបានព្រះវិហារថ្មី។ វាក៏ជាលិទ្ធផលនៃការខិតខំប្រឹងប្រែង របស់បងប្អូនគ្រីស្តបរិស័ទយ៉ាងសកម្មនៅក្នុងការបន្តជំនឿ និងថែ-រក្សាជំនឿ។

លោក ប៉ូល បានប្រាប់ទៀតថា ៖ លោកចាប់អារម្មណ៍ខ្លាំងនៅពេលដែលមកដល់ព្រះសហគមន៍អ្នកលឿងនេះ គឺលោកត្រូវពង្រីកការអប់រំដល់យុវជននិងកុមារ ព្រោះវាសំខាន់បំផុត ដើម្បីឲ្យយុវជនក៏ដូចជាកុមារ មានចំណេះដឹងទូលំទូលាយអាចរស់នៅក្នុងសង្គមបានស្រួល។

ដោយសាព្រះសហគន៍កាតូលិកមួយនេះ មានតែគ្រីស្តបរិស័ទ ដែលជាជនជាតិវៀតណាម។ក្នុងធម្មទេសនាលោកអូលីវីយេក៏បានជម្រុញ ឲ្យបងប្អូនគ្រីស្តបរិស័ទ បើកចិត្តទូលាយ ក្នុងការផ្តល់សក្ខីភាពពីវត្តមានរបស់ព្រះយេស៊ូ ក្នុងការរស់នៅ ក៏ដូចជាធ្វើសមាហរណ្ឌកម្មជាមួយអ្នកភូមិផ្សេងៗទៀត។ បើកទ្វារព្រះវិហារ ដើម្បីឲ្យអ្នកដទៃអាចពឹងពាក់យើងបាន។

ព្រះសហគមន៍កាតូលិក អ្នកលឿង មានគ្រីស្តបរិស័ទ ប្រមាណជា ៥០០ គ្រួសារ មានមនុស្សចំនួនប្រមាណជាង ១០០០នាក់។ ព្រះវិហារថ្មីនេះ បានចំណាយថវិការសាងសង់អស់ទឹកប្រាក់សរុបប្រមាណជិត ៥ម៉ឺនដុល្លារអាមេរិក ដែលបានមកពីការចូលរួម របស់បងប្អូនគ្រីស្តបរិស័ទក្នុង និងក្រៅប្រទេស៕

*ដោយស្រីម៉ាច*

## យុវជនអំពៅព្រៃ ថែវិកាជួយអ្នកក្រខ្សត់

យុវជននៃព្រះសហគមន៍អំពៅព្រៃ នៃមណ្ឌលសកម្មភាពតាខ្មៅ បានចុះសួរសុខទុក្ខគ្រួសារក្រីក្រ និងអ្នកជំងឺ ចំនួន៣២គ្រួសារ ស្ថិតក្នុងភូមិតាដោល ឃុំអំពៅព្រៃ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៥កន្លងមកនេះ។

យុវនារីផល្លា សុខចាន់ ដែលជាមេក្រុមយុវជនបានឲ្យដឹងថា ៖ ការមកសួរសុខទុក្ខនេះ និងជូនទាននេះ គឺមានគោលបំណង ចង់លើកទឹកចិត្ត និងបង្ហាញសេចក្ដីស្រលាញ់ ដល់ជនចាស់ជរា និងអ្នកជំងឺ។ សុខចាន់បន្តថា ក្រុមយុវជនក៏ចង់បង្ហាញឲ្យយុវជន យុវនារី ដែលរស់នៅជុំវិញព្រះសហគមន៍យល់ពីការស្រលាញ់ មេត្តាករុណា ដែលយើងត្រូវធ្វើចំពោះអ្នកក្រខ្សត់ផងដែរ។

សុខចាន់ បានឲ្យដឹងទៀតថា សម្ភារ និងគ្រឿងឧបភោគទាំងនេះ គឺយើងបានចែកជូនដល់គ្រួសារចាស់ជរា ២គ្រួសារ និងគ្រួសារអ្នកជំងឺ១គ្រួសារ ដែលថវិការទាំងនេះ បានមកពីការរៃអង្គាសពីក្រុមយុវជន នៃព្រះសហគមន៍ដោយផ្ទាល់៕

**ដោយសំនៀង**

# អគ្គសញ្ញាលាបថ្វាសឲ្យគ្រីស្តបរិស័ទចេះដាក់ខ្លួន និងសម្ដែងមេត្តាករុណា

គ្រីស្តបរិស័ទ ចំនួន៣៣នាក់ទទួលអគ្គសញ្ញាលាបថ្វាស នៅព្រះវិហារព្រះ-បេះដូងព្រះយេស៊ូ (ព្រះសហគមន៍កោះនរា) កាលពីថ្ងៃទី១៤ មិថុនា ២០១៥នេះ ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ឆ្មឹតអឺស្លែរ និងលោកបូជាចារ្យ នៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង រួមជាមួយគ្រីស្តបរិស័ទ ជាង ៤០០នាក់ ។



*លោកអភិបាលអូលីវីយេធ្វើអគ្គសញ្ញាលាបថ្វាសឲ្យគ្រីស្តបរិស័ទ។ រូបថតៈ សុធីរិទ្ធិ*

បេក្ខជន ប៉ូឡូ ជាសុខា មកពីព្រះសហគមន៍តួតាំងបានឲ្យដឹងថា៖ "អគ្គ-សញ្ញាលាបថ្វាសនេះ ពិតជាសំខាន់សម្រាប់ខ្ញុំ ព្រោះថា ខ្ញុំបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធមកបំភ្លឺចិត្តគំនិត និងផ្ដល់កម្លាំងកាយចិត្ត ដើម្បីប្រកាសដំណឹងល្អអំពីព្រះជាម្ចាស់ ដោយស្ដាប់ព្រះបន្ទូល ចេះសម្ដែងចិត្តមេត្តាករុណាចំពោះអ្នកឯទៀត និងចេះស្រឡាញ់គ្នាទៅវិញទៅមក"។

រីង លី វណ្ណា បានប្រាប់ដែរថា ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំគាត់ឲ្យចេះដាក់ខ្លួន មិនមានភាពអាត្មានិយម តែឲ្យយល់ពីអ្នកដទៃ។ លោកបន្តថា លោកនឹងខិតខំកសាងព្រះសហគមន៍ ដោយព្យាយាមស្រឡាញ់ព្រះយេស៊ូគឺស្រឡាញ់បងប្អូនដទៃទៀត ព្រោះពួកយើងគឺជាគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្ត។

អគ្គសញ្ញាលាបថ្វាស ជាពិធីមួយបន្ទាប់ពីអគ្គសញ្ញាជ្រមុជទឹក ដែលធ្វើឲ្យក្លាយជាគ្រីស្តបរិស័ទពេញលក្ខណៈ ។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ លើកទឹកចិត្តគ្រីស្តបរិស័ទទាំងអស់ ជាពិសេសបេក្ខជនដែលទើបតែទទួលអគ្គសញ្ញាលាបថ្វាសទាំងនោះថា ព្រះជាម្ចាស់ បានជ្រើសរើសយើងទាំងអស់គ្នា ដែលជាមនុស្សតូចតាច ដើម្បីធ្វើឲ្យគម្រោងការរបស់ព្រះអង្គបានរីកចម្រើនឡើង គឺមានន័យថា យើងជាមនុស្សតូចតាច តែយើងមានសម្ថភាពមកពីព្រះជាម្ចាស់ ដើម្បីបង្កើតសង្គមថ្មី ដែលជាព្រះរាជ្យព្រះជាម្ចាស់ ដោយយកព្រះនាងម៉ារីជាគំរូ គឺត្រូវទុកចិត្តលើព្រះជាម្ចាស់ មានការអត់ធ្មត់ និងដាក់ខ្លួនជាអ្នកបម្រើ ដោយស្រឡាញ់គ្នាទៅវិញទៅមក ដែលជាកេរ្តិ៍មរតកដែលព្រះយេស៊ូបានទុកឲ្យយើង។

លោកបូជាចារ្យ ខូន អាប្រាហាំ ជាអ្នកទទួលខុសត្រូវ ព្រះសហគមន៍នេះ បានឲ្យដឹងថា៖ បេក្ខជនដែលទទួលអគ្គ-សញ្ញាលាបថ្វាសនៅថ្ងៃនេះ ព្រះសហ-គមន៍ឲ្យពួកគាត់ចូលរួម ក្នុងក្រុមព្រះបេះដូងព្រះយេស៊ូ ដែលធ្វើឲ្យពួកគាត់នៅជិតស្និទ្ធជាមួយព្រះស៊ូ តាមរយៈសកម្មភាពព្រះសហគមន៍ ។

បេក្ខជនទាំង ៣៣នាក់នេះ មកពីព្រះសហគមន៍ ២កន្លែង នៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង គឺព្រះសហគមន៍តួតាំង៩នាក់ និងព្រះសហ-គមន៍កោះនរាចំនួន២៤នាក់៕ *ដាលីស*

# ក្រុមមេត្តាករុណាយកចិត្តទុកដាក់អំពីគ្រួសារក្រីក្រ

ក្រុមមេត្តាករុណា នៃព្រះសហគមន៍ព្រះត្រៃឯកគិរីវង់ ដែលស្ថិតនៅក្នុងភូមិព្រៃជើង ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ ដែលមានសមាជិក ៥នាក់ បានទៅសួរសុខទុក្ខ និង នាំយកនូវគ្រឿងឧបភោគបរិភោគ ដល់គ្រួសារដែលមានវ័យចាស់ជរា និងមានជីវភាពខ្វះខាតកាលពីថ្ងៃអាទិត្យ ទី០៧ ខែមិថុនា ឆ្នាំ២០១៥កន្លងទៅនេះ។

តាមសម្ដីរបស់លោកតា សុខ ដែលជាប្រធានក្រុមមេត្តាករុណា បានឲ្យដឹងថា៖ ជារៀងរាល់ខែ ក្រុមនេះមានគោលដៅធ្វើសកម្មភាពនេះ ដល់គ្រួសារចំនួន២គ្រួសារ។ លោកតាសុខ ឲ្យដឹងទៀតថា ក្នុង១ខែម្ដងក្រុមមេត្តាករុណានះមានសកម្មភាពជួយដល់អ្នកក្រីក្រចាស់ជរា និងអ្នកជំងឺ ដោយផ្ដល់ជាម្ហូបអាហារ គ្រឿងឧបភោគបរិភោគ និងបញ្ជូនអ្នកជំងឺ ទៅកាន់មន្ទីរពេទ្យជាដើម។

នៅក្នុងខែនេះ ក្រុមមេត្តាករុណាបានសួរសុខទុក្ខដល់គ្រួសារ លោកតាយិន ដែលមានអាយុ ៨១ឆ្នាំ និងគ្រួសារលោកយាយពៅដែលមានអាយុ ៨៦ ឆ្នាំ ដែលកំពុងមានជីវភាពខ្វះខាតជា ខ្លាំង និង មានភាពចាស់ជរាមិនអាចធ្វើការងារអ្វីបាន។ លោកយាយគាត់ខ្វិនដោយសារគាត់ ត្រូវបានស្វិតជើងទាំងសងខាង ហើយគាត់បានរស់នៅជាមួយ និងកូន ស្រីរបស់គាត់ដែលនៅលីវមានអាយុ ៥០ឆ្នាំ និងមានជំងឺទៀត។

ជាមួយគ្នានេះដែរ លោកយាយពៅដែលមានអាយុ៨៦ឆ្នាំ ស្វិតជើងទាំងសងខាង កំពុងរស់នៅជាមួយកូនស្រីរបស់គាត់ បានមានប្រសាសន៍ថា ៖ "ខ្ញុំមានអំណរសប្បាយ និងរំភើបជាខ្លាំង រកអ្វីមកប្រៀបផ្ទឹមពុំបាននោះទេ ព្រោះខ្ញុំកំពុងតែខ្វះខាត បានមីមួយកេះ ទឹកត្រី ទឹកស៊ីអ៊ីវ ប្រេងឆា ទឹកត្រចៀកកាំមួយឃ្លួ អាចជួយដោះស្រាយជីវភាពខ្ញុំបានមួយរយៈពេលដែរ"៕

*ដោយសុខណាន*



រូបថត: លី សុវណ្ណា

# បិទកម្មវិធីអប់រំជំនឿ ឆ្នាំសិក្សា ២០១៤-២០១៥

ព្រះសហគមន៍កា តូលិកបាត់ដំបងក្រុង ប្រារព្ធពិធីបិទកម្មវិធីអប់រំជំនឿកាតូលិក ឆ្នាំ២០១៤-២០១៥ កាលពីថ្ងៃទី ២៨ ខែមិថុនា កន្លងទៅ ក្រោមវត្តមានលោក ហ្វីការេដូ អេនរីគេ ជាអភិបាល ព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ជាអធិបតី និងមានការចូលរួមពីសំណាក់លោកបូជាចារ្យ ដូនជី លោកគ្រូ អ្នកគ្រូអប់រំជំនឿ ព្រមទាំងសិស្សានុសិស្សប្រមាណជាជាង ២០០ នាក់។

នៅក្នុងពិធីនេះ សិស្សតាមក្រុមនីមួយៗបានខិតខំ បញ្ចេញនូវសមត្ថភាពរបស់គេរៀងៗខ្លួន លើផ្នែកចំរៀង រាំ និងកាយវិការផ្សេងៗតាមបទចំរៀងកាតូលិក និងសម័យជាដើម។

ដូនជី យ៉ាវ៉ាសាង លក្ខិណា ជាអ្នកសម្របសម្រួលកម្មវិធី អប់រំជំនឿនៅព្រះសហគមន៍កាតូលិកព្រះវិហារ ព្រះជាម្ចាស់លើកព្រះនាងម៉ារី ឡើងស្ថានបរមសុខ បានមានប្រសាសន៍ជាស់តឿនដល់ប្អូនទាំងអស់ឲ្យបន្ត យកចិត្តទុកដាក់ចូលរួមអភិបូជារៀងរាល់ថ្ងៃអាទិត្យ ដើម្បីស្តាប់ព្រះបន្ទូលព្រះជាម្ចាស់។ ក្នុងនោះដែរដូនជីរូបនេះ ក៏បានអរគុណដល់អ្នកណែនាំជំនឿទាំងអស់ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត។

តាមប្រសាសន៍លោក តូតែត ជាបូជាចារ្យទទួលខុសត្រូវ ព្រះសហគមន៍នេះមានប្រសាសន៍ថា ពេលនេះថ្នាក់ទាំងអស់ត្រូវសម្រាក ហើយគ្រូអប់រំជំនឿក៏ផុតភារកិច្ចរបស់គេដែរ។ លោកថាពួកគេបានសន្យាទទួលភារកិច្ចនេះ មួយឆ្នាំម្តង។ពេលចូលវគ្គថ្មីបើគេចូលម្តងទៀត គេត្រូវចុះឈ្មោះ និងបន្តមុខងារនេះទៀតមួយឆ្នាំម្តងៗ។

លោអភិបាល អេនរីកេ ហ្វីការេដូ មានប្រសាសន៍ ទៅកាន់កុមារទាំងអស់ថា៖ "សូមកូនៗអនុវត្តនូវអ្វីៗដែលកូនបានរៀនជាមួយលោកគ្រូអ្នកគ្រូ គឺការអធិដ្ឋាន និងស្តាប់ព្រះបន្ទូល"។ លោកបន្តថា ចូរកូនប្រព្រឹត្តខ្លួនឲ្យបានល្អ កុំនិយាយកុហក់ ឬពាក្យអាក្រក់ៗជាដើម។

លោកក៏បានផ្តាំផ្ញើ ចំពោះយុវជនយុវតី ដែលពេញនិយមប្រព័ន្ធបណ្តាញសង្គមហ្វេសប៊ុក សូមប្រើដោយត្រឹមត្រូវប្រើដើម្បីអប់រំជំនឿ។ ចូរកុំប្រើដើម្បីគ្រាន់តែបង្ហាញពីខ្លួនឯង ឬបង្ហាញអារម្មណ៍មនោសញ្ចេតនារបស់ខ្លួនឡើយ ។

នៅក្នុងពិធីនេះក៏មានចែករង្វាន់ដល់សិស្ស ដែលប្រលងបានចំណាត់ថ្នាក់ ពីលេខ ១-៣ ផងដែរ។ ព្រមទាំងមានអំណោយជាស្បែកជើង ដល់សិស្សទាំងអស់តាមថ្នាក់នីមួយៗ និងមានដំណើរកំសាន្តផងដែរ។ថ្នាក់អប់រំជំនឿនេះមានចំនួន១១ថ្នាក់ មានសិស្សចំនួន ២១៥ នាក់។ ពួកគេមកទទួលការអប់រំជារៀងរាល់ថ្ងៃអាទិត្យ នៅព្រះវិហារ នៃព្រះសហគមន៍កាតូលិកបាត់ដំបងក្រុង៕

## កម្មវិធីប្រកួតបាល់ទាត់ ភូមិភាគកំពង់ចាម

ព្រះសហគមន៍ កាតូលិកកំពង់ចាមបានរៀបចំកម្មវិធីប្រកួតបាល់ទាត់ ជាលក្ខណៈមិត្តភាពសម្រាប់យុវជនកាលពីថ្ងៃទី១៨មិថុនាកន្លងទៅ នៅតារាងបាលទាត់មួយកន្លែង ស្ថិតនៅជិតព្រះវិហារកំពង់ចាមក្រុង ក្នុងខេត្តកំពង់ចាម ដែលមានអ្នកគាំទ្រ សរុបប្រមាណជិត ១០០នាក់។

លោក ហេង ៉ារី ជាគណៈកម្មការទទួលខុសត្រូវកម្មវិធីយុវជន នៅភូមិភាគកំពង់ចាមបានឲ្យដឹងថា៖ នេះជាកម្មវិធីរបស់យុវជនដែលធ្វើឡើងដើម្បីអោយយុវជនចេះចាប់អារម្មណ៍ និងវិស័យកីឡា មិនសំដៅតែលើបាល់ទាត់ គឺផ្នែកកីឡាទាំងអស់ ព្រោះថា ការហាត់កីឡាក៏ជាចំណែកមួយ ក្នុងការជួយសម្រួលសុខភាពបានដែរ។

ការប្រកួតនេះ ត្រូវបានចែកចេញជា៦ក្រុម ដែលក្រុមនីមួយៗមកពីព្រះសហគន៍ចំនួន៤ក្នុងតំបន់កំពង់ចាម។ លទ្ធផលលេខ១ បានទៅខាងមណ្ឌលយុវជនបុរស៕

*ដោយ: ស្រីម៉ាច*



រូបថត: ៉ារី



## សូមអញ្ជើញចូលរួមបុណ្យឆ្លងព្រះវិហារ
## សន្តីម៉ារីម៉ាដាឡា ស្វាយប៉ាក

យើងខ្ញុំលោកបូជាចារ្យ បងស្រី និងគ្រិស្តបរិស័ទ ព្រះសហគមន៍សន្តីម៉ារី ម៉ាដាឡា ស្វាយប៉ាក។

សូមគោរពអញ្ជើញលោកបូជាចារ្យ បងប្រុស បងស្រី និងគ្រិស្តបរិស័ទទាំងអស់ ចូលរួមអភិបូជា អរព្រះគុណព្រះជាម្ចាស់ ឆ្លងព្រះសហគមន៍ប្រចាំឆ្នាំ នៅព្រះសហគមន៍ស្វាយប៉ាក។ ក្រោមអធិបតីភាព របស់លោកបូជាចារ្យកាលេ ណានី ឆារលេស (Fr.Charles)។ វេលាម៉ោង ៩.៣០ ព្រឹក ថ្ងៃសៅរ៍ទី ២៥ ខែកក្កដា ឆ្នាំ ២០១៥។

# មរណភាពរបស់អ្នកម្ដាយនៀម៉ាឡា យ៉ូស្សីនៃក្រុមមេត្តាករុណា ( MOC )



អ្នកម្ដាយ នៀម៉ាឡា យ៉ូស្សីបានទទួលមរណភាពនៅថ្ងៃទី ២២ ខែមិថុនា ក្នុងប្រទេសឥណ្ឌា។
រូបថត: ??????????

បងស្រីនៀម៉ាឡា យ៉ូស្សី ( Nirmala Joshi ) ជាអ្នកម្ដាយធំ របស់ក្រុមបងស្រីមេត្តាករុណាទូទាំងពិភពលោកបានទទួលមរណភាព កាលពីថ្ងៃទី ២២ មិថុនា កន្លងទៅ ក្នុងជន្មាយុ៨១ឆ្នាំ នៅទីក្រុងកាលគូតានៅក្នុងប្រទេសឥណ្ឌា។

តាមប្រភពព័ត៌មាននានា បានឲ្យដឹងថាបងស្រីជាដូនជីម្នាក់ ដែលពូកែជំរុញទឹកចិត្ត ផ្ដល់ភាពកក់ក្ដៅ ភាពរីករាយរួសរាយរាក់ទាក់ និងការប្ដេជ្ញាចិត្តក្នុងការជួយអ្នកក្រីក្រ និងជនទុរគ៌តជិតស្លាប់។

បងស្រីនៀម៉ាឡា យ៉ូស្សី ជាអ្នកម្ដាយធំទី២ បន្ទាប់ពីអ្នកម្ដាយតេរេសា ដែលជាអ្នកបង្កើតក្រុមគ្រួសារនេះ ។ បងស្រីនៀម៉ាឡា យ៉ូស្សី ប្រសូតក្នុងគ្រួសារដែលសាសនាហិណ្ឌូ នៅទីក្រុង Ranchi នៃប្រទេសឥណ្ឌា ក្នុងឆ្នាំ ១៩៣៤។ បងស្រីនៀម៉ាឡា យ៉ូស្សី ទទួលបានការអប់រំ ពីសាសនទូតកាតូ-លិក ហើយបានផ្លាស់ប្ដូរជំនឿ មកជាគ្រីស្តបរិស័ទកាតូលិក។ គាត់បានបញ្ចប់ការសិក្សា កំរិតអនុបណ្ឌិត ផ្នែកនយោបាយ។ ក្រោយមក បងស្រីបានចូលរួមក្នុងក្រុមគ្រួសារ បងស្រីមេត្តាករុណា ដែលបានបង្កើត និងដឹកនាំដោយអ្នកម្ដាយតេរេសា។ ក្រោយមក បងស្រី ត្រូវបានជ្រើសតាំងឲ្យក្លាយជាអ្នកម្ដាយធំ បន្ទាប់ពីអ្នកម្ដាយតេរេសា ក្នុងឆ្នាំ១៩៩៧-២០០៩។ បច្ចុប្បន្ន បងស្រីធំនៃក្រុមគ្រួសារនេះ គឺបងស្រីម៉ារី ព្រីម៉ា ( Sr. Mary Prema )។

នៅក្នុងប្រទេសកម្ពុជា ក្រុមគ្រួសារបងស្រីមេត្តាករុណា មានវត្តមាននៅ៣កន្លែង និងមានក្រុមបងប្រុស១កន្លែងផងដែរ ដែលក្រុមគ្រួសារនេះធ្វើការជិតស្និទ្ធជាមួយអ្នកក្រីក្រ និងកុមារកំព្រា។ កម្មវិធីទាំងនោះមានដូចជា មណ្ឌលថែទាំអ្នកជំងឺ ដែលគេបោះបង់ចោល

# ព្រះសហគមន៍ជុំគីរីទិញដីនិងសង់ផ្ទះជូនអ្នកក្រីក្រ

ព្រះសហគមន៍ ជុំគីរី នៃមណ្ឌលសកម្មភាពកំពតបានទិញដី និងបានសាងសង់ផ្ទះ ដែលមានបណ្ដោយ ៥ ម៉ែត្រ និងទទឹង ៤ម៉ែត្រ ឲ្យអ្នកដែលទីទ័លក្រខ្លាំងក្នុងភូមិ កាលពីកាលពីពាក់កណ្ដាលខែមិថុនានេះ ដោយមានការជួយជ្រោមជ្រែងផ្នែកកម្លាំង ពីក្រុមយុវជន នៃព្រះសហគមន៍នេះផងដែរ។

លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកាជា អ្នកទទួលខុសត្រូវមណ្ឌលសកម្មភាពព្រះសហគមន៍កំពតទាំងមូល បានឲ្យដឹងថា ដីនិងផ្ទះមួយខ្នងនេះត្រូវប្រគល់ជូនលោកទូចនិងអ្នកស្រី យិន ដែលជាគ្រួសារក្រីក្រខ្លាំង កំពុងរស់នៅក្នុងភូមិជុំគិរីស្រុកឈូកខេត្តកំពត ដែលមានកូនក្នុងបន្ទុក៦នាក់ រកព្រឹកខ្វះល្ងាច។

ទំហំដីដែលព្រះសហគមន៍បានទិញនោះ គឺមានទំហំប្រមាណជិតកន្លះហិចតា សម្រាប់ឲ្យគ្រួសារនេះប្រកបការងារចិញ្ចឹមជីវិត។

លោកលូកាបានបន្តថា ព្រះសហគមន៍មានបំណងសម្ដែងធម៌មេត្តាករុណាដល់បងប្អូនឯទៀតដោយត្រូវជួយគ្នាទៅវិញទៅមកដូចបងប្អូនបង្កើតដើម្បីបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូចំពោះយើងទាំងអស់គ្នា និងក៏ជារបៀបប្រកាសដំណឹងល្អដល់អ្នកក្រីក្រ។

លោកបូជាចារ្យ បានបង្ហើបឲ្យដឹងទៀតថា៖ "ព្រះសហគមន៍មានគំរោងជួយសាងសង់ផ្ទះដល់អ្នកក្រីក្រទីទាល់ខ្លាំង ចំនួន៣ផ្ទះបន្ថែមទៀតនាពេលខាងមុខឆាប់ៗនេះ ដោយអាស្រ័យទៅលើថវិការ និងកម្លាំងដើម្បីឲ្យពួកគេមានផ្ទះនៅសមរម្យ"។

កន្លងមក ព្រះសហគមន៍ជុំគិរីមានសកម្មភាពជាច្រើន ដូចជាចុះសួរសុខទុក្ខអ្នកក្រីក្រ ចាស់ជរា បញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ផ្ដល់អាហាររូបករណ៍ដល់សិស្សក្រីក្រជាដើម៕

*ដោយដាលីស*

# បុណ្យរំឮកព្រះបេះដូងព្រះយេស៊ូនៅព្រះសហគមន៍កោះនរា

ព្រះសហគមន៍កោះនរា នៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានប្រារព្ធពិធីបុណ្យ រំឮកដល់ព្រះបេះដូងព្រះយេស៊ូដែលជាឧបការី នៃព្រះសហគមន៍នេះក្រោមអធិបតីភាព លោកអភិបាលអូលីវីយេផ្មីតហាស្លីរ៉េ និងលោកបូជាចារ្យទាំងអស់ ដែលមានបន្ទុកដឹកនាំព្រះសហគមន៍កាតូលិក នៃមណ្ឌលសកម្ម-ភាពនេះរួមជាមួយគ្រីស្តបរិស័ទប្រមាណជាង៤០០នាក់។

កម្មវិធីនេះប្រព្រឹត្តទៅ នៅព្រឹកថ្ងៃទី ១៤មិថុនា ដោយមានការអធិដ្ឋានដង្ហែរូបសំណាកព្រះបេះដូងព្រះយេស៊ូ ជាមួយចម្រៀង លើកតម្កើងព្រះជាម្ចាស់យ៉ាងឱឡារិកជុំវិញព្រះវិហារ ចំនួន៣ជុំ ដើម្បីរំឮកដល់សេចក្ដីស្រឡាញ់ដ៏ធំធេងរបស់ព្រះយេស៊ូរហូតបូជាព្រះជន្មសម្រាប់មនុស្សលោក។



រូបថត:សុធីរិទ្ធិ

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ថា ព្រះបេះដូងរបស់ព្រះយេស៊ូ គឺជាព្រះហឫទ័យ នៃសេចក្ដីស្រឡាញ់។ លោកបានបន្ដណែនាំគ្រីស្តបរិស័ទទាំងអស់ ឲ្យខិតខំរស់នៅស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺធ្វើយ៉ាងណាឲ្យព្រះជាម្ចាស់ សប្បាយព្រះទ័យ ដោយកែប្រែចិត្តគំនិតជឿលើដំណឹងល្អ និងខិតខំអនុវត្តតាមព្រះបន្ទូលព្រះជាម្ចាស់ និងទៅជាព្រះកាយព្រះយេស៊ូទាំងកម្លាំងកាយចិត្ត ដើម្បីជាសាក្សី នៃសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ។

លោកខូនអាប្រាហាំ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នេះ បានឲ្យដឹងថា ៖ ព្រះសហគមន៍នេះ ក៏មានក្រុមបេះដូងព្រះយេស៊ូ ដែលតែងតែយកចិត្តទុកដាក់អធិដ្ឋាន និងមានសកម្មភាពមេត្តាករុណា។ មិនតែប៉ុណ្ណោះ អ្វីដែលសំខាន់ជាងគេ គឺចេះរស់នៅតាមព្រះហឫទ័យព្រះជាម្ចាស់ គឺចេះមានទំនាក់ទំនងល្អជាមួយគ្នា ដោយចិត្តស្រឡាញ់របស់ព្រះយេស៊ូ និងដោយនឹកឃើញដល់អ្នកដទៃដោយបង្កើតទំនាក់ទំនងថ្មីជាមួយពួកគេដោយសេចក្ដីស្រឡាញ់គឺបន្តសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ជាមួយអ្នកដទៃ។

*ដោយដាលីស*



*លោកបូជាចារ្យ ហ្វ្រង់ស័រ ប៉ុងសូដ៍។*

## ៥ កក្កដា ត្រូវនឹងថ្ងៃអាទិត្យ ទី១៤ ក្នុងរដូវធម្មតា (មក ៦:១-៦) លោកយេស៊ូជាមនុស្សសុទ្ធសាធ

តាមធម្មតា យើងធ្លាប់និយាយអំពី "ព្រះយេស៊ូ" ហាក់ដូចជាព្រះមួយអង្គ ដែលដឹងអ្វីៗទាំងអស់ អាចធ្វើអ្វីៗទាំងអស់បាន។ល។ រីឯក្នុងអត្ថបទនេះ លោកមាកូស រៀបរាប់អំពី លោកយេស៊ូត្រឡប់ទៅភូមិស្រុករបស់ខ្លួន លោកជួបបងប្អូន ញាតិមិត្ត ដែលងឿងឆ្ងល់យ៉ាងខ្លាំង។ គេធ្លាប់ស្គាល់កុមារយេស៊ូតាំងពីតូចមក គឺលោកជាកូននាងម៉ារី និងលោកយ៉ូសែប កាលពីតូចវាធ្លាប់ទៅសាលារៀន ដូចកុមារាកុមារីឯទៀតៗ គេធ្លាប់ស្គាល់ពូយេស៊ូ ជាជាងដែលតែងតែធ្វើការឲ្យគេ មានបងប្អូននៅភូមិនោះ។ល។ ក្នុងចំណោមអ្នកភូមិ គ្មាននរណាស្គាល់ឋានៈ ដ៏លាក់កំបាំងរបស់លោក សូម្បីតែនាងម៉ារីក៏មិនដឹងដែរ។ គេគ្រាន់តែរាប់បងយេស៊ូនេះ ទុកជាព្យាការីម្នាក់ ដែលនិយាយក្នុងព្រះនាមរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ហេតុនេះអត្ថបទនេះរំឭកយើងឲ្យនឹកថា លោកយេស៊ូជាមនុស្សសុទ្ធសាធ ដូចយើងម្នាក់ៗដែរ។ តែបងយេស៊ូ បែរទៅកាន់ព្រះបិតាក្នុងគ្រប់កិច្ចការដែលលោកធ្វើ។ លោកជាមនុស្ស ដែលនឹកគិតដល់ព្រះបិតាជានិច្ច។ ទាំងនាងម៉ារី ទាំងក្រុមសាវ័កស្គាល់ឋានៈ ដ៏អាថ៌កំបាំងរបស់លោកយេស៊ូ តែនៅពេលក្រោយ គឺនៅពេលលោកទទួលព្រះជន្មថ្មីដ៏រុងរឿង។ យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ ក៏មិនមែនជាមនុស្សប្លែកពីអ្នកដទៃទេ តែយើងជឿថា យើងជាបុត្រធីតារបស់ព្រះបិតា។ យើងអាចគាប់ព្រះហឫទ័យ ព្រះបិតាបាន ដោយរស់នៅតាមរបៀបជាធម្មតា ធ្វើការជាធម្មតា យើងមិនធ្វើអ្វីដ៏អស្ចារ្យទេ តែក្នុងគ្រប់កិច្ចការយើងនឹកគិតដល់ព្រះបិតាជានិច្ច ដូចបងយេស៊ូនោះដែលបានរស់នៅជាមនុស្ស តាមរបៀបព្រះជាម្ចាស់។ ហេតុនេះ ជីវិតធម្មតារបស់យើងមានតម្លៃ។

## ១២ កក្កដា ត្រូវជាអាទិត្យ ទី១៥ ក្នុងរដូវធម្មតា (មក៦:៧-១៣)

ព្យាការីយេស៊ូចាត់សាវ័ករបស់លោកឲ្យទៅប្រកាសថា ព្រះជាម្ចាស់ជិតយាងមកគ្រងរាជ្យលើស្រុកយូដា គឺបន្តិចទៀត ព្រះអង្គនឹងរំដោះប្រជាជនឲ្យបានសេរីភាព និងសេចក្តីសុខសាន្តដ៏ពិតប្រាកដ។លោកចាត់សាវ័កពីនាក់ម្តងៗ មិនមែនតែម្នាក់ៗទេ! ដូច្នេះគេអាចសម្តែងសេចក្តីស្រឡាញ់គ្នានឹងគ្នា ។ លោកមិនឲ្យគេយកអ្វីសម្រាប់ធ្វើដំណើរ កុំយកអាហារ កុំយកប្រាក់កាស ឬអាវបន្លាស់ទេ តែត្រូវធ្វើជីវិតទាំងស្រុងលើព្រះជាម្ចាស់ប៉ុណ្ណោះ។ សាសវ័កទាំងនោះ ក៏ដូចលោកសង្ឃនៃពុទ្ធសាសនាដែរ គេមិនជំពាក់ជំពិននឹងអ្វីៗឡើយ។ លោកចាត់គេឲ្យទៅព្យាបាល អ្នកជំងឺតាមរបៀបគ្រូពេទ្យនៅសម័យនោះ។នេះជាសញ្ញាសម្គាល់បញ្ជាក់ថា គេអាចរំដោះអ្នកស្រុកឲ្យរួចពីជំងឺរោគាព្យាធិ និងពីខ្មោច ដែលជានិមិត្តរូបអំពីសេចក្តីអាក្រក់នានា ដែលតែងតែរាំងមនុស្សលោកមិនឲ្យបានសេចក្តីសុខសាន្ត ដ៏ពិតប្រាកដ។ "ត្រូវប្រែចិត្តគំនិត" គឺបែរមុខទៅរកព្រះបិតា ដែលគ្រងរាជ្យលើខ្លួន។ តើសព្វថ្ងៃ មានអ្វីដែលរាំងផ្លូវយើងមិនឲ្យបានសេចក្តីសុខសាន្តដ៏ពិតប្រាកដ? តើសព្វថ្ងៃ យើងជាគ្រីស្តបរិស័ទជួយរំដោះមនុស្ស ដែលរស់នៅជាជុំវិញយើង ឲ្យរួចពីសេចក្តីអាក្រក់ទាំងនោះយ៉ាងដូចម្តេច ?

## ១៩ កក្កដា ត្រូវជាអាទិត្យទី១៦ ក្នុងរដូវធម្មតា (មក ៦:៣០-៣៤)

លោកយេស៊ូ និងសាវ័ករួមគ្នាសម្រាកក្រោយពីបាន បំពេញបេសកកម្មដើមដំបូង។ អ្នកស្រុករត់មកសូមព្យាការីយេស៊ូ និង សាវ័កព្យាបាលគេឲ្យបានជា។ គួរឲ្យឆ្ងល់ គឺគម្ពីរចែងថា "ព្រះយេស៊ូ មានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់" (ពាក្យនេះអាណិតអាសូរ សំដៅលើចិត្តរបស់ម្តាយដែលអាណិតកូន)តែព្រះអង្គមិនជួយព្យាបាលគេ ផ្ទុយទៅវិញ លោកបែរជាបង្រៀនអំពីសេចក្តីជាច្រើន"។សេចក្តីនេះសរឲ្យយើងដឹងថា មុខងាររបស់ព្រះសហគមន៍ គឺនាំឲ្យប្រជាជនខ្មែរយើង ស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាចំពោះគេម្នាក់ៗ។ នេះជាបេសកកម្មច្បងរបស់យើងម្នាក់ៗ ព្រះសហគមន៍មិនមែនជាអង្គការមនុស្សធម៌ទេ តែជាក្រុមអ្នកដែលធ្វើជីវិតលើព្រះបិតា និងរកឃើញរបៀបរស់នៅថ្មីប្រកបដោយសេចក្តីសុខសាន្ត។ កិច្ចការទាំងអស់ ដែលយើងជាគ្រីស្តបរិស័ទ ធ្លាប់ធ្វើតាមផ្លូវមនុស្សធម៌ មានគោលដៅតែមួយ គឺនាំឲ្យគេជាពិសេសអ្នកតូចតាច អ្នកដែលត្រូវគេមើលងាយ អ្នកក្រីក្រ ឲ្យដឹងថា ជីវិតគេមានតម្លៃ ព្រោះគេជាបុត្រធីតារបស់ព្រះបិតាតែមួយព្រះអង្គ ជាព្រះបិតាដែលស្រឡាញ់គេ។ យើងដឹងច្បាស់ថា ពិបាកនិយាយអំពីព្រះបិតា ដែលគេមិនទាន់ស្គាល់នោះទេ តែរបៀបរស់នៅរបស់យើងអាចផ្តល់សក្ខីភាពថា ទាំងយើងទាំងអ្នករស់នៅជុំវិញយើង មានព្រះបិតាតែមួយ យើងក៏ស្រឡាញ់គ្នា និងជួយគ្នាទៅវិញទៅមកដូចបងប្អូនបង្កើត។

## ២៦ កក្កដា ត្រូវជាអាទិត្យទី១៧ ក្នុងរដូវធម្មតា (យហ ៦:១-១៥)

តាមធម្មតា ពេលយើងអានអត្ថបទនេះ យើងនឹកភ្លាមថា ព្រះយេស៊ូបានសម្រេចការអស្ចារ្យមួយ គឺព្រះយេស៊ូបង្កើននំប៉័ង ចែកឲ្យមហាជនបរិភោគឆ្អែត។ តែអត្ថបទនេះ មានអត្ថន័យជ្រៅជាង។ លោកយ៉ូហាន ប្រៀបធៀបព្យាការី យេស៊ូនឹងលោកម៉ូសេដែលបានណែនាំប្រជាជនអ៊ីស្រអែល កាលពីដើមឲ្យរួចពីស្រុកអេស៊ីប និងចូលទៅក្នុងទឹកដីសន្យា។ ព្យាការីយេស៊ូឡើងលើភ្នំ ដូចលោកម៉ូសេឡើងលើភ្នំស៊ីណៃ ដើម្បីទទួលធម្មវិន័យ។ ព្យាការីយេស៊ូប្រទានព្រះបន្ទូល ដែលជាអាហារដ៏ពិតប្រាកដសម្រាប់មនុស្សយើង ដូចកាលពីដើមលោកម៉ូសេ បានផ្តល់នំម៉ាណ្ណា ដូច្នោះដែរ។ ខាងចុងអត្ថបទព្យាការីយេស៊ូចែកនំប៉័ងនិងត្រីឲ្យប្រជាជន ដូចលោកចែកនំប៉័ង និងស្រានៅថ្ងៃព្រហស្បតិ៍មុនពេលត្រូវគេឆ្កាង។ បានសេចក្តីថា ព្រះយេស៊ូ មានព្រះបន្ទូលតែមួយគត់ ដែលជាអាហារ ដ៏ពិតប្រាកដសម្រាប់យើង គឺព្រះអង្គបូជាព្រះជន្មថ្វាយព្រះបិតាដោយសេចក្តីស្រឡាញ់។ សាវ័កមិនយល់ស្រប ហើយនាំគ្នាប្រកែកជំទាស់។ យើងជាគ្រីស្តបរិស័ទនឹងចែកព្រះបន្ទូលទុកជាអាហារ ដល់ប្រជាជនខ្មែរ លុះត្រាស់តែយើងសុខចិត្តបូជាជីវិតសម្រាប់អ្នកដទៃ ដូចព្រះបរមគ្រូរបស់ខ្លួន៕

---

## កំណាព្យ

## យុវជនស្ម័គ្រចិត្តបម្រើសង្គម

*និពន្ធដោយអ្នកស្រី ខុង ណារី*

*( បទពាក្យ ៧ )*

១- យុវជនជាកងកម្លាំងមួយ    បម្រើលើកស្ទួយក្នុងសង្គម
ទឹកចិត្តស្នេហាប្រមូលផ្តុំ    ដើម្បីសង្គមឥតគេចកែ ។
២- វប្បធម៌ប្រពៃណីជាតិយើង    រក្សារុងរឿងកេរ្តិ៍ឈ្មោះខ្មែរ
សម្បត្តិធម្មជាតិឆ្លៀតជួយថែ    កុំបំផ្លាញខ្មែរកំណើតខ្លួន ។
៣- ការងារសង្គមឧត្តមក្រៃ    ត្រូវជួយកែច្នៃទើបសមសួន
ពង្រឹងស្មារតីចាំជាប់ជួន    ឲ្យរឹងមាំមួនទំនុកចិត្ត។
៤- ចាប់យកការងារដែលសំខាន់    មិនក្រែងប្រកាន់ដក់គំនិត
លំឱនចិត្តកាយដោយលម្អិត    ជួយដោយស្មោះពិតគិតថាត្រូវ។

៥-ការងារបរិសុទ្ធយុត្តិធម៌    ទទួលគ្រោកអរដឹកនាំទៅ
គំរូបវរគ្មានអាស្រូវ    គោលការណ៍សំដៅភាពសុខសាន្ត។
៦-មិនថាសង្គមតូចតាចក្តី    ទឹកចិត្តភក្តីគ្រប់អង្គប្រាណ
បម្រើសង្គមទ្រទ្រង់ស្ថាន    ជាញាតិសន្តានលំអានខ្មែរ ។
៧-បេះភ្ជាក់រឭកនឹកជួយគ្នា    យុវជនពុះពាររក្សាថែ
វីរយុវជនគន់ពូកែ    ជឿជាក់ឥតប្រែថៃប្រតិបត្តិ ។
៨-កំពូលយុវជនតែងមានឈ្មោះ    រន្ទឺពិរោះរសាយសាត់
ក្នុងក្រាំងប្រវត្តិឥតមានខ្ចាត់    កិត្តិនាមគ្មានស្ងាត់ក្នុងប្រទេស។
៩-ដូច្នេះត្រូវជួយដោយជំហរ    ស្មារតីគាំទ្រកុំប្រហែស
លះបង់ចិត្តកាយចាយចំណេះ    មិនឲ្យរបេះប្រេះឆាឡើយ៕



# វិទ្យាស្ថានសន្តប៉ូល

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ
Tel: 032 639 0002/ 032 639 0003 | E: spi.takeo@gmail.com | W : www.spi.edu.kh

## ថ្នាក់បរិញ្ញាបត្រ

វិស្វកម្មកម្មវិធី Software Engineering

**មហាវិទ្យាល័យព័ត៌មានវិទ្យា**
Faculty of Information Technology

- វិស្វកម្មកម្មវិធី Software Engineering
- ទូរគមនាគមន៍ និងបណ្តាញ
  Telecommunication and Network

**ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស**
Department of English Literature

- អប់រំភាសាអង់គ្លេស
  Teaching English as Foreign Language
- ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង
  English for Communication

**ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍**
Department of Tourism Management

- គ្រប់គ្រងទេសចរណ៍
  Tourism Management

**ដេប៉ាតឺម៉ង់កសិកម្មសាស្ត្រ**
Department of Agronomy

- កសិកម្មសាស្ត្រ
  Agronomy

**ដេប៉ាតឺម៉ង់សង្គមកិច្ច**
Department of Social Work

- សង្គមកិច្ច
  Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- **អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ**
  Software Development
- **គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ**
  System and Network Administration
- **បង្រៀនភាសាអង់គ្លេសជាភាសាទីពីរ**
  Teaching English As Second Language
- **សណ្ឋាគារ និងបដិសណ្ឋារកិច្ច**
  Hotel and Hospitality
- **ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ**
  Fruit and Vegetable Crop Production
- **ជំនាញកែច្នៃអាហារ**
  Food Processing
- **ប្រព័ន្ធកសិកម្មចម្រុះ**
  Integrated Farming System
- **ថែទាំកុមារ**
  Child care

## លក្ខខណ្ឌចូលរៀន

សម្គាល់៖ រៀនបន្ថែម២ឆ្នាំនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រ

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២)
ឬសញ្ញាបត្រដែលមានតម្លៃស្មើសម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២. បេក្ខជនធ្លាក់ថ្នាក់ទី១២ អាចចូលរៀន
ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

## ចាប់ផ្តើមលក់ពាក្យ និងទទួលពាក្យ

- ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៥
- ចូលរៀនឆមាសទី១ ខែវិច្ឆិកា ឆ្នាំ២០១៥

## ចាប់ពីថ្ងៃនេះតទៅ